ឧបសម្ព័ន្ធ ១

# របាយការណ៍បូកសរុប

# ប្រចាំឆ្នាំ២០១៦



# អង្គការកែប្រែសហគមន៍

មាតិការ

I. អំពីអង្គការកែប្រែសហាគមន៍
II. ពត៌មានគម្រោង
III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង
IV. របាយការណ៍ហិរញ្ញវត្ថុ
V. ឧបសគ្គរាំងស្ទះនិងមេរៀន
VI. ផែនការទិសដៅការងារបន្ត

## I. អំពីអង្គការកែប្រែសហគមន៍

អង្គការកែប្រែសហគមន៍ Community Translation Organization, (CTO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៩៣ សជណ ថ្ងៃទី៣០ ខែ មិនថុនា ឆ្នាំ ២០០៩។ ស្នាក់ការកណ្តាលរបស់អង្គការមានទីតាំងស្ថិតអាគារបុរីប្រឹមប្រិយ ផ្ទះលេខ សេ២៧ ផ្លូវក្ងម៉ៃ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ ដែលជាទីតាំងយុទ្ធសាស្រ្តមួយសម្រាប់សម្របសម្រួលកិច្ចការអភិវឌ្ឍន៍ សម្រាប់ខេត្តក្នុងភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដូចជាខេត្ត សៀមរាប ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ។ អង្គការកែប្រែសហគមន៍ ធ្វើការងារដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់សហគមន៍ដែលអាស្រ័យផលនឹងរបរកសិកម្មដោយផ្តោតលើការងារកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការកសាងសមត្ថភាពក្រុមកសិករគំរូដែលមានដូចជាក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍ទេសចរធម្មជាតិ សហគមន៍កសិកម្ម និងជម្រុញការអភិវឌ្ឍន៍តាមប្រជាធិបតេយ្យ ការអប់រំផ្សព្វផ្សាយដល់សហគមន៍លើបញ្ហាបម្រែបម្រួលអាកាសធាតុ ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យធម្មជាតិដើម្បីឆ្ពោះទៅរកការកសាងសហគមន៍ដែលធន់ទ្រាំទៅនឹងបញ្ហាសង្គមនិងសេដ្ឋកិច្ច។ អង្គការកែប្រែសហគមន៍ ធ្លាប់ជាកម្មវិធីមួយរបស់អង្គការ Human Translation (គេហទំព័រ www.humantranslation.org) ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ ក្នុងឆ្នាំ២០០៩ តាមរយៈការកែទម្រង់ អង្គការកែប្រែសហគមន៍ បានប្រែក្លាយមកជាអង្គការឯករាជ្យក្នុងស្រុកមួយ ដែលបានចុះបញ្ជីស្របច្បាប់ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

- បាវចនា ៖ ប្រែក្លាយចំណេះដឹងទៅជាសកម្មភាព
- ទស្សនវិស័យ ៖ កសិករអាចធ្វើកិច្ចការដើម្បីកែលំអរជីវភាព និងសេដ្ឋកិច្ចបានប្រសើរឡើងនៅពេលដែលពួកគាត់ទទួលបាននូវសម្ភារៈ ចំណេះដឹង ជំនាញ និងធនធានសមស្រប
- បេសកកម្ម ៖ ចូលរួមជាមួយសហគមន៍ ដើម្បីការត់បន្ថយភាពក្រីក្រ អភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អេកូទេសចរណ៍ និងធ្វើអោយប្រសើរឡើងនូវការចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរនិងមានការការគោរពសិទ្ធិសេរីភាពពេញលេញ។

### ក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| Tobias Rose-Stockwell | ប្រធានស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល | California, USD E-mail: tobias@humantranslaionn.org |
| Jon Morgan | សមាជិកក្រុមប្រឹក្សាភិបាល /ប្រធាន LAKECLINIC.org | សាលាកំរើក ក្រុងសៀមរាប E-mail: jmorgan@lakeclinic.org |
| Kat Bun Heng | សមាជិកក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប E-mail: kat.bunheng@gmail.com |
| Kristen Davies | សមាជិកក្រុមប្រឹក្សាភិបាល ទីប្រឹក្សា GIZ ប្រចាំសៀមរាប | សាលាកំរើក ក្រុងសៀមរាប E-mail : kdavies025@gmail.com |

### បុគ្គលិកលេខាធិការដ្ឋាន/

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|
| លោក ឃិញ យ៉ា | នាយកប្រត្តិបត្តិ(ពេញម៉ោង) | សៀមរាប | ០១២៧០៧៤៧៤ |
| លោក ស្រីសៀង សុធារី | អ្នកគ្រប់គ្រងហិរញ្ញវត្ថុ(ពេញម៉ោង) | សៀមរាប | ០១២៤៥១៨៧៧ |
| លោក ថៃពិសី | អ្នកសម្រួលសម្រួលកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៦២២១៨១ |
| លោក ម៉យ រ៉ាមន | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៧២៨១៩២ |
| លោក សួន វាសនា | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៥៥៣០១៣ |
| លោកស្រី វេត រដ្ឋា | មន្ត្រីរដ្ឋបាល(ពេញម៉ោង) | សៀមរាប | ០៨៥៥៥៨៨៩៥ |
| លោក រិត បូ | ប្រធានសម្របសម្រួលខេត្ត(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣៥១៦៩៦ |
| លោកស្រី ទេព សាម៉េត | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩២៥០២៦២០ |
| លោក បូ គីមី | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩៣៦០៣០៣០ |
| លោកស្រី លួម សុខណា | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៧២៦៣៧៦ |
| លោកស្រី ធឹក សុផា | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៦៧៩៥៣៥៥ |
| កញ្ញា សួន សោភា | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៩៩១៨០៥០ |
| លោក ទឹន សុខហឿន | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០១២២៩៩៧១១ |
| លោក ជន ចំណាន | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០១២៩៨០៤២៥ |
| លោក ស្រី ប៊ុន | មន្ត្រីគម្រោង(ក្រៅម៉ោង) | សៀមរាប | ០៩២៩៣២៤៣០ |
| កញ្ញាទីវ សាវន្តែ | ជំនួយការរដ្ឋបាល និងអ្នកសំអាត(ពេញម៉ោង) | សៀមរាប | ០៩៩៧០១៣៧៣ |
| កញ្ញាសាមោន សុភិន | អ្នកស្ម័គ្រចិត្ត | សៀមរាប | ០៩០៨៥៥៨៦០ |
| Mr. Mathieu Dupouy | អ្នកស្ម័គ្រចិត្ត | បារាំង | |
| Mr. Gabriel Therond | អ្នកស្ម័គ្រចិត្ត | បារាំង | |
| Ms. Lena Conti | អ្នកស្ម័គ្រចិត្ត | បារាំង | |
| Ms.Camile | អ្នកស្ម័គ្រចិត្ត | បារាំង | |

**ប្រភពថវិកា**(ឆ្នាំកន្លងមក ៥ ក្នុងរយៈពេល) **ជំនួយ/**

| ឈ្មោះម្ចាស់ជំនួយ/ មូលនិធិ | អាស័យដ្ឋាន | ប្រភេទនៃកម្មវិធី | ប្រភេទនៃជំនួយ ជំនួ/ប្រាក់កម្ចី) (យ | រយៈពេល | ស្ថានភាព បញ្ច/បន្តកំពុងដំណើរការ) ប់ ប្រសិនបើបញ្ចប់សូមប ញ្ជាក់ថ្ងៃ ខែ ឆ្នាំ បញ្ចប់( |
|---|---|---|---|---|---|
| WEEFFECT/SIDA | SWEDEN | សេដ្ឋកិច្ចកសិកម្មសហគម | ជំនួយ | ៥ឆ្នាំ | បន្តរ |
| Actionaid-Cam | Cambodia | ពង្រឹងសិទ្ធមូលដ្ឋាន | ជំនួយ | ៦ឆ្នាំ | បន្តរ |
| UNDP SGP/CCBAP | Cambodia | Climate Change and Natural resources | ជំនួយ | ១.៨ឆ្នាំ | បន្ត |
| OXFAM GB | Cambodia | ព្រៃសហគម ជីវភាព | ជំនួយ | ២ ឆ្នាំ | បញ្ចប់ និង កំពុងដាក់គំរោងបន្តរ |
| 100WOMEN.Org | Australia | Women Small Business | ជំនួយ | 1 ឆ្នាំ | បញ្ចប់ |
| AusAID | Cambodia | Farmer Economy | ជំនួយ | 3 ឆ្នាំ | បញ្ចប់ |
| UNDP SGP/CCBAP | Cambodia | Climate Change and Natural resources | ជំនួយ | 2 ឆ្នាំ | បញ្ចប់ |

**វិស័យផ្នែកដែលផ្តោតការយកចិត្តទុកដាក់/**

| ប្រភេទនៃកម្មវិធី សកម្មភាព/គម្រោង/ | ទីកន្លែង | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកាជំនួយ / | ស្ថានភាព បញ្ចប់ /បន្តកំពុងដំណើរការ) ប្រសិនបើបញ្ចប់ (សូមបញ្ជាក់ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ | សៀមរាប | ៣ឆ្នាំ | -ក្រុមប្រឹក្សឃុំ<br>-ការិយាល័យអប់រំស្រុក | Actionaid | បញ្ចប់ ០១មេសា២០១៦ |
| និយ័តកម្មព្រៃឈើ ទឹកស្អាតនិងអនាម័យ | ព្រះវិហារ | ៣ ឆ្នាំ | -សហគមន៍ព្រៃឈើ<br>-រដ្ឋបាលព្រៃឈើ<br>-មន្ទីរអភិវឌ្ឍន៍ជនបទ | OXFAM GB | បញ្ចប់ ០៨សីហា២០១៥ |
| អេកូទេសចរណ៍ គ្រប់គ្រងធនធានធម្មជាតិ បំរែបំរួលអាកាសធាតុ ការចិញ្ចឹមជីវិត | សៀមរាប | ២ ឆ្នាំ | ក្រុមប្រឹក្សឃុំ | UNDP SGP | បញ្ចប់ ៣០ធ្នូ២០១៣ |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៧ឆ្នាំ | សហគមអភិវឌ្ឍកសិកម្ម | SIDA/WEFFECT | បន្ត |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៥ ឆ្នាំ | មន្ទីរកសិកម្ម | AusAID | បញ្ចប់ ០៦កក្កដា២០១៤ |
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ គ្រប់គ្រង់គ្រោះមហន្តរាយ | ឧត្តរមានជ័យ | ៧ឆ្នាំ | -បណ្តាញស ហាគន៍ព្រៃឈើ<br>-បណ្តាញគាំទ្រសហគមន៍ | Actionaid | បន្ត |
| គ្រប់គ្រងធនធានធម្មជាតិ បំរែបំរួលអាកាសធាតុ ការចិញ្ចឹមជីវិត | សៀមរាប | ១.៨ ឆ្នាំ | ក្រុមប្រឹក្សឃុំ<br>ឧទ្យានជាតិ<br>រដ្ឋបាលស្រុក | UNDP SGP | កំពុងអនុវត្តន៍ |

## II. ពត៌មានគម្រោង

គម្រោងទី១

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងជម្រុញភាពសកម្មនិងសេវាកម្មសហគមន៍កសិកម្មនៅខេត្តសៀមរាប |
| គោលដៅរួម | ចូលរួមកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋតាមរយៈការពង្រឹងសេដ្ឋកិច្ចកសិករ និងសមត្ថភាពអង្គការសហគមន៍ |
| តំបន់គោលដៅ | -ខេត្តៈ សៀមរាប<br>-ស្រុកៈ ពួក ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ស្រុកសូត្រនីគមន៍<br>-ឃុំៈ កែវពណ៌ សំរោងយា ពួក ត្បែង ខ្នាស់ ត្រពាំងធំព្រះដាក់ រលួស កន្ទ្រាំង |
| ក្រុមគោលដៅ | សហគមន៍កសិកម្ម ១២ ក្រុមសន្សំ២៥ក្រុម សហភាពសហគមន៍កសិកម្ម១ យុវជនកំរិតអនុវិទ្យាល័យ៣០០នាក់ |

| | |
|---|---|
| អ្នកទទួលផលផ្ទាល់ | ១៤៨៦គ្រួសារ |
| អ្នកទទួលផលប្រយោល | ៣០០០នាក់ ស្ត្រី ១៥៨៨នាក់ |

គម្រោងទី២

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីសិទ្ធិមូលដ្ឋាន (LRP) |
| គោលដៅរួម | កសិករ និងកុមារក្រីក្រនៅក្នុងតំបន់គោលដៅរបស់គម្រោងនឹងទទួលបាននូវសន្តិសុខស្បៀង និងឱកាសទទួលបានការសិក្សាប្រសើរជាងមុន ដោយពួកគេមានលទ្ធភាពទទួលបាននូវសិទ្ធិជាមូលដ្ឋាន ហើយអនុវត្តសិទ្ធិទាំងនោះតាមផ្លូវច្បាប់ដើម្បីរស់នៅប្រកបដោយភាពថ្លៃថ្នូរនៅក្នុងសង្គម។ |
| តំបន់គោលដៅ | -ខេត្ត: ឧត្តរមានជ័យ<br>-ស្រុក: សំរោង បន្ទាយអំពិល ចុងកាល់ អន្លង់វែង<br>-ឃុំ: សំរោង បន្សាយរាក់ កូនក្រៀល គោកខ្ពស់ ពង្រ លំទង |
| ក្រុមគោលដៅ | សហគមន៍ព្រៃឈើ ៤ ក្រុមសន្សំ៨ក្រុម បណ្តាញសហគមន៍ព្រៃឈើខេត្ត១ ក្រុមជង្រុកស្រូវ ៨ សាលាបឋមសិក្សា២០ |
| អ្នកទទួលផលផ្ទាល់ | ១៨៦៣គ្រួសារ |
| អ្នកទទួលផលប្រយោល | ៩៣៣៨នាក់ ស្រី៤៧៥០នាក់ ក្នុងនោះកុមារសរុប៣២៦៨នាក់ |

## III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង

គម្រោងទី១



| ផ្នែកទី១-ការផ្តល់បច្ចេកទេសកសិកម្ម | | |
|---|---|---|
| គោលបំណង | លទ្ធផល | សកម្មភាពអន្តរគមន៍ជាគន្លឹះ |
| ១-ការផ្តល់បច្ចេកទេសកសិកម្ម | ១.១-ផ្តល់ចំណេះដឹងទៅលើបច្ចេកទេសដំណាំស្រូវដល់កសិករ និងណែនាំការអនុវត្តបច្ចេកទេសថ្មីនៅតាមកសិដ្ឋានស្រូវគំរូ<br>១.២-ផ្តល់ចំណេះដឹងទៅលើបច្ចេកទេសដំណាំបន្លែ និងណែនាំការអនុវត្តបច្ចេកទេសថ្មីនៅតាមកសិដ្ឋានបន្លែគំរូឬជាដំណាំចម្រុះ<br>១.៣-ផ្តល់ចំណេះដឹងទៅលើបច្ចេកទេសនៃការចិញ្ចឹមសត្វ និងណែនាំការអនុវត្តបច្ចេកទេសថ្មីនៅតាមកសិដ្ឋានចិញ្ចឹមសត្វគំរូ | -វគ្គបណ្តុះបណ្តាលសិក្សាតម្រូវការ<br>-ចងក្រងមេរៀននិងសម្ភារៈគាំទ្រការបណ្តុះបណ្តាលអំពើដំណាំស្រូវ<br>-ចុះប្រជុំត្រួតពិនិត្យផ្ទាល់ជាប្រចាំ និងផ្តល់ដំបូន្មានតាមទីតាំងកសិដ្ឋានគម្រូ<br>-ផ្តល់វគ្គបណ្តុះបណ្តាល និងគាំទ្រផ្ទាល់សម្រាប់ការចាប់ផ្តើមផែនការដាំដុះ<br>-អនុវត្តនៅលើកសិដ្ឋានបង្ហាញគម្រូ<br>-ផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់កសិករឆ្នើម<br>-ប្រជុំចែករម្លែកបទពិសោធន៍ និងចំណេះដឹងជុំវិញការអនុវត្តគម្រោងទៅកាន់ភូមិគោលដៅ និងក្រៅគូលដៅ |

| ផ្នែកទី២-ការធ្វើសកម្មភាពកសិកម្មបែបពាណិជ្ជកម្ម និងទីផ្សារ | | |
|---|---|---|
| គោលបំណង | លទ្ធផល | សកម្មភាពអន្តរគមន៍ជាគន្លឹះ |
| ២-ការធ្វើសកម្មភាពកសិកម្មបែបពាណិជ្ជកម្ម និងទីផ្សារ | ២.១-កសិករមានសមត្ថភាពផ្តោតឆ្ពោះលើការអនុវត្តការដាំដំណាំបន្លែ និងឈើហូបផ្លែដែលមានតំលៃខ្ពស់លើទីផ្សារ | -វិភាគតម្រូវការទីផ្សារនូវប្រភេទបន្លែ ដំណាំហូបផ្លែដែលជាផលិតផលមានតម្លៃខ្ពស់នៅលើទីផ្សារ<br>-ចងក្រងមេរៀន និងសម្ភារៈគាំទ្រការបណ្តុះបណ្តាលអំពើដំណាំបន្លែនិងឈើហូបផ្លែ(របៀបចាប់ផ្តើមជំនួររបៀបទទួល លពត៌មានទីផ្សារកសិសេដ្ឋកិច្ច |

| | | |
|---|---|---|
| | ២.២-កសិករមានសមត្ថភាពផ្តោតឆ្ពោះលើជំនាញផ្នើមផ្នែកទីផ្សារ និងការធ្វើជំនួញ | និងរបៀបកត់ត្រាបញ្ជីរស្នាម។ល។<br>-កសាងសមត្ថភាពអំពីបច្ចេកទេសដំណាំ បន្លែឈើហូបផ្លែដែលមានតម្លៃខ្ពស់នៅលើទីផ្សារ(ការបន្សុតពូជការជ្រើសរើសពូជ..។ល។) ហើយនិងធ្វើការគាំទ្រអនុវត្ត ផ្ទាល់នៅទីវាល<br>-ចុះប្រជុំត្រួតពិនិត្យផ្ទាល់ជាប្រចាំ និងផ្តល់ដំបូន្មានតាមទីតាំងកសិដ្ឋានគម្រូ<br>-ផ្តល់វគ្គបណ្តុះបណ្តាលរបៀបធ្វើជំនួញ និងមូលដ្ឋានគ្រឹះគ្រប់គ្រងហិរញ្ញវត្ថុ<br>-អនុវត្តនៅលើកសិដ្ឋានបង្ហាញគម្រូ<br>-ផ្លាស់ប្តូរទស្សនកិច្ចសិក្សា<br>-ប្រជុំចែករម្លែកបទពិសោធន៍ និងចំណេះដឹងជុំវិញការអនុវត្តគម្រោងទៅកាន់ភូមិក្នុង និងក្រៅគោលដៅ |

**ផ្នែកទី៣- គាំទ្រ និងបង្កើតសហាគមន៍កសិកម្ម និងក្រុមសន្សំប្រាក់**

| គោលបំណង | លទ្ធផល | សកម្មភាពអន្តរគមន៍ជាគន្លឹះ |
|---|---|---|
| ៣-គាំទ្រ និងបង្កើតសហាគមន៍កសិកម្ម និងក្រុមសន្សំប្រាក់ | ៣.១-ផ្តល់ការគាំទ្របន្ថែមទៅលើក្រុមសន្សំប្រាក់ដែលបង្កើតរួចហើយ<br><br>៣.២-ចលនានិងគាំទ្របង្កើតក្រុមសន្សំប្រាក់ថ្មីបន្ថែម | -ចុះសិក្សាតម្រូវការ និងប្រមូលទិន្នន័យគោលក្រុមសន្សំ និងសហាគមន៍កសិកម្ម<br>-ប្រជុំផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹងអំពីអត្ថប្រយោជន៍របស់សហាគមន៍កសិកម្ម និងក្រុមសន្សំប្រាក់<br>-ចងក្រងមេរៀន និងសម្ភារៈគាំទ្រការបណ្តុះបណ្តាលផ្អែកលើតម្រូវការជាក់ស្តែងដែលបានកំណត់(ជំនាញគ្រប់គ្រង គណនេយ្យ និងគោលការប្រតិបត្តិការក្រុម..។ល។)<br>-ចុះប្រជុំត្រួតពិនិត្យផ្ទាល់ជាប្រចាំ |

| | | |
|---|---|---|
| | ៣.៣-ចលនានិងគាំទ្របង្កើតសហគមន៍កសិកម្ម | និងផ្តល់ដំបូន្មានទៅលើដំណើរការក្រុម<br>-ផ្តល់វគ្គបណ្តុះបណ្តាល<br>និងគាំទ្រផ្ទាល់សម្រាប់ការចាប់ផ្តើម(សម្ភារៈចាប់ផ្តើមស្នាក់ការ..។ល។)<br>-ផ្លាស់ប្តូរទស្សនកិច្ចសិក្សា<br>-ប្រជុំចែករម្លែកបទពិសោធន៍<br>និងចំណេះដឹងជុំវិញការអនុវត្តគម្រោងទៅកាន់ភូមិគោលដៅ<br>និងក្រៅគូលដៅ |

| ផ្នែកទី៤-ការគ្រប់គ្រងគម្រោងកម្មវិធី | | |
|---|---|---|
| គោលបំណង | លទ្ធផល | សកម្មភាពអន្តរគមន៍ជាគន្លឹះ |
| ៤-ការគ្រប់គ្រងគម្រោងកម្មវិធី | ៤.១-កសាងផែនការគម្រោងការត្រួបពិនិត្យ វាយតម្លៃផ្ទៃក្នុងហើយនឹងការសម្របសម្រួលអោយស្របទៅនឹងតម្រូបការរបស់វីអេហ្វិច<br><br>៤.២-រៀបចំរបាយការណ៍ទៀងទាត់ស្របតាមតម្រូវការរបស់វីអេហ្វិក | -ប្រជុំកសាងផែនការប្រចាំឆ្នាំ<br>ផែនការសកម្មភាពប្រចាំខែ<br>-ការចុះត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង<br>និងពីវីអេហ្វិករៀងរាល់ត្រីមាស<br>-រៀបចំរបាយការណ៍ហិរញ្ញវត្ថុរៀងរាល់២ខែ<br>និងផ្តល់របាយការណ៍រីកចំរើន២ដងក្នុង១ឆ្នាំ<br>-ចូលរួមប្រជុំកម្មវិធីជាមួយដៃគូទាំងអស់២ដងក្នុង១ឆ្នាំ<br>-ការចុះវាយតម្លៃពីអ្នកជំនាញឯករាជ្យម្តង់ក្នុង១ជំហ៊ាន<br>-ការធ្វើសវនកម្មគម្រោងរៀងរាល់១ឆ្នាំម្តង |

**<u>វិភាគលទ្ធផល</u>**

សេដ្ឋកិច្ចខេត្តសៀមរាបមានកំនើនឡើងយ៉ាងឆាប់រហ័ស ដែលជាចំបងគ្របដណ្តប់ដោយវិស័យទេសចរណ៍ ដោយបានបង្កើតការងារជាច្រើនជាពិសេសដល់ប្រជាជនក្នុងប្រជុំជនក្រុងសៀមរាប ដែលប្រជាជនទាំងនេះមានជីវភាពរស់នៅប្រសើរជាងបើប្រៀបធៀបទៅនឹងអ្នកដែលរស់នៅជនបទ ដែលពួកគេនៅប្រឈមនឹងបញ្ហាខ្វះស្បៀងអាហារ ហើយនឹងការទទួលបាននូវអាហារូបត្ថម្ភគ្រប់គ្រាន់ជាពិសេសស្ត្រីនិងកុមារ ដោយកត្តាទិន្នផលកសិកម្មទាបហើយដែលជីវភាពពួកគាត់ពឹងផ្អែក

ស្ទើរតែទាំងស្រុងទៅលើផលកសិកម្មនេះ។ កង្វះអាហារូបត្ថម្ភគឺជាចំណែកមួយដែលបណ្តាលអោយមានអត្រាមរណៈកុមារកើតមានឡើង។ កុមារប្រមាណជាជាង ១៩០០នាក់ ដែលមានអាយុទាបជាង៥ឆ្នាំជាអត្រាស្លាប់ក្នុងពេលឆ្លងទន្លេសម្រាប់រយៈពេលប្រាំឆ្នាំនៅទូទាំងស្រុកនៃខេត្តសៀមរាបរហូតដល់ឆ្នាំ២០០៩។ ដោយសារការនាំមុខនៃសេដ្ឋកិច្ចមកពីវិស័យឧស្សាហកម្មទេសចរណ៍ ធ្វើអោយខេត្តសៀមរាបក្លាយជាទីផ្សារដ៏ធំស្រូបទាញយកផលិតផលកសិកម្ម ដែលអាចផ្តល់ឱកាសដ៏មានសក្តានុពលដល់កសិករក្នុងខេត្តសៀមរាប ជាពិសេសស្រុកគោលដៅដែលនៅជិតជុំវិញក្រុងសៀមរាប។ ម្យ៉ាងវិញទៀតដោយយោងទៅលើការសិក្សាស្រាវជ្រាវ និងមេរៀនបទពិសោធន៍ដែលទទួលបានពីការជួបប្រជុំផ្ទាល់ជាមួយអ្នកពាក់ព័ន្ធគម្រោង បានរកឃើញថាកសិករក្រីក្រនៅតែមិនអាចជ្រៀតចូលបានទៅក្នុងចរន្តទីផ្សារនេះនៅឡើយ ដោយផ្អែកលើស្ថានភាពជាក់ស្តែងទីផ្សារនេះត្រូវការការផ្គត់ផ្គង់ក្នុងបរិមាណច្រើន ដោយធានានូវការផ្គត់ផ្គង់ដោយទៀងទាត់ និងមានគុណភាពដែលអាចប្រកួតប្រជែងទៅនឹងផលិតផលមកពីខាងក្រៅ ដែលជាទូទៅកសិករមិនទាន់អាចមានលទ្ធភាពឆ្លើយតបបានដោយកត្តាខ្វះជំនាញផលិត និងការគាំទ្រសេវាកម្ម។ សរុបមក គម្រោងគឺស្ថិតក្នុងទំរង់នៃការអភិវឌ្ឍសហគមន៍ ដែលអ្នកទទួលផលគម្រោងកំពុងរស់នៅក្នុងសហគមន៍ ជាអ្នកដែលប្រកបរបរបង្កបង្កើនផលនៃខេត្តសៀមរាប។ ដើម្បីសម្រេចបាននូវគោលបំណងគម្រោងសម្រាប់ឆ្នាំ ២០១៦ អង្គការកែប្រែសហគមន៍ និងអង្គការវីអេហ្វិក បានព្រមព្រៀងបន្តទៅពង្រីកវិសាលភាពអោយកាន់តែធំទូលាយដើម្បីជួយទៅដល់ចលានសហគមន៍កសិកម្មហើយនឹងជំនួញសេវាកម្ម តាមរយៈគម្រោងដែលមានឈ្មោះថា ជម្រុញចលនាសហគមន៍កសិកម្ម និងសេវាកម្មរបស់សហគមន៍ក្នុងខេត្តសៀមរាប។ ការចងក្រងបង្កើតជាសហភាពសហគមន៍កសិកម្មគឺជាគោលបំណងគន្លឹះសម្រាប់ដំណាក់កាលទីពីរនេះ។ ភាគច្រើន និយមន័យនៃការងារអភិវឌ្ឍសហគមន៍ត្រូវបានប្រជាពលរដ្ឋនិងអាជ្ញាធរដែនដីក្នុងភូមិគេគិតថាជាការងារដែលផ្តោតតែលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តទោះយ៉ាងណាគម្រោងនេះមានការយល់ដឹងទូលំទូលាយទៅនឹងគោលគំនិតនៃការងារអភិវឌ្ឍជាមួយប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន ដែលវាមិនចាំបាច់គាំទ្រផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះទេ ប៉ុន្តែវាពាក់ព័ន្ធទៅនឹងការពង្រឹងការយល់ដឹងសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ការពង្រឹងអំណាចម្ចាស់ការទាំងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចទៅដល់ប្រជាកសិករ និងអង្គការសហគមន៍របស់ពួកគេផងដែរ ដោយមានការកសាងសមត្ថភាពទៅដល់ ក្រុមជួយខ្លួនឯង សមាគមសន្សំ និងកំចីភូមិ សហគមន៍ និងសហភាពសហគមន៍កសិកម្មជាដើម។ ប្រជាកសិករ និងអាជ្ញាធរមូលដ្ឋានក្នុងតំបន់គោលដៅគម្រោងចាប់ផ្តើមយល់តម្លៃរបស់វាបន្តិចម្តងនិងបានចូលរួមសកម្មជាមួយគម្រោង។ សុរបទៅ ទាំងប្រជាកសិករនិងភាគីពាក់ព័ន្ធគម្រោងយល់ស្របថា ក្រុមជួយខ្លួនឯង សមាគមសន្សំនិងកំចីភូមិ សហគមន៍ និងសហភាពសហគមន៍កសិកម្ម គឺជាហេដ្ឋារចនាសម្ព័ន្ធប្រភេទទន់ដែលជាគន្លឹះ ដែលអាចចូលរួមចំណែកទៅលើនិរន្តភាពនៃកិច្ចខិតខំសម្រាប់ការងារអភិវឌ្ឍសហគមន៍ដូចគ្នាដែរ។ គម្រោងដែលយើងរៀបចំឡើងគឺដើម្បីបើកទ្វារអោយសហគមន៍ខ្លួនឯងអាចមើលឃើញពីស្ថានភាពរបស់ពួកគេផ្ទាល់ បន្ទាប់មកអាចចាត់ចែងដោះស្រាយវា ដើម្បីឆ្ពោះទៅកាន់អនាគតមួយដ៏ត្រឹមត្រូវដោយខ្លួនឯង។ តាមរយៈសកម្មភាពគន្លឹះដែលគ្រោងក្នុងគម្រោង យើងអាចធ្វើការដោះស្រាយយ៉ាងសកម្មទៅលើបញ្ហាជាច្រើនដែលកើតមានក្នុងសហគមន៍។ អ្វីដែលជាមោទនភាពដែលយើងសម្រេចបានជាលទ្ធផលចំបងៗដូចតទៅ៖

- ចំនួនអង្គការសហគមន៍មានការកើនឡើង ដែលយើងបានចាប់ផ្តើមពីពេលដែលមិនមានសហគមន៍កសិកម្មសោះ ហើយនឹងក្រុមសន្សំប្រាក់៣៥ ដែលទន់ខ្សោយគ្រប់គ្រង រហូតពេលនេះយើងបានបង្កើតសហគមន៍កសិកម្មបានចំនួន ៣ ដែលមានសមាជិកសរុប ១៨៤គ្រួសារ ក្រុមសន្សំប្រាក់ចំនួន ២៥ក្រុម អាចដើរដោយឯករាជ្យខ្លួនឯងយ៉ាងសកម្មក្នុងការផ្តល់ការសេវាដល់សមាជិក ដែលមានកំនើនសមាជិក ៣៥%បន្ថែមលើសមាជិកចំនួន ៩០៥នាក់ដែល

ចាប់ផ្តើមដំបូង។ ហើយចំណែកក្រុមដែលសេសសល់ផ្សេងទៀតនៅត្រូវការការជួយគាំទ្រពីអង្គការសហគមន៍នៅឡើយ។ យើងបានធ្វើសមាហរណកម្មនូវចំណេះដឹងវ័យឆ្លាតថ្មីៗផ្នែកកសិកម្មតាមកសិដ្ឋានគម្រូ មានដូចជាការចិញ្ចឹមសត្វ ដំណាំស្រូវ ដំណាំឈើហូបផ្លែ ដំណាំបន្លែ ផ្សេងៗទៅដលសមាជិករបស់សហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់ទាំងនោះ ដើម្បីអាចធ្វើពិសោធន៍នូវបច្ចេកទេសដែលរៀនសូត្រថ្មីៗទៅធ្វើការកែលំអរការអនុវត្តខុសឆ្គងកន្លងមក ហើយនិងធ្វើការអនុវត្តចំនេះដឹងដែលបានរៀនសូត្រទាំងនេះយកទៅពង្រីកផ្សព្វផ្សាយ និងអនុវត្តបន្តដើម្បីទទួលបានជោគជ័យ។

- យើងរកឃើញថា ៨០%នៃសមាជិកសរុបរបស់ក្រុមសន្សំប្រាក់ និង៦០%នៃសមាជិកសហគមន៍កសិកម្មគឺជាស្ត្រី ហើយដែលស្មើរតែ៩០%ក្នុងក្រុមសន្សំប្រាក់ និង៣៥%ក្នុងសហគមន៍កសិកម្មមានស្ត្រីកាន់តំណែងក្នុងជួរថ្នាក់ដឹកនាំក្រុម។ យើងតែតែជម្រុញការពង្រឹងការចូលរួមរបស់ស្ត្រីយ៉ាងសកម្មនៅក្នុងគ្រប់កំរិតទាំងអស់ ជាពិសេសនៅក្នុងកំរិតសម្រេចចិត្ត ហើយទោះបីជានៅមានឧបសគ្គរាំងកើតឡើងខ្លះៗក៏ដោយ ក៏យើងនៅតែមានសុទិដ្ឋិនិយមថាតាមរយៈគម្រោងនេះគឺពិតជាអាចផ្តល់ប្រយោជន៍ច្រើន ដល់ស្ត្រីតាមរយៈការប្រើប្រាស់ឧបករណ៍FRASដែលបានណែនាំអោយអនុវត្តក្នុងគម្រោងដោយអង្គការវីអេហ្វិក។
- ចំនួនសហគមន៍កសិកម្មដែលគម្រោងគាំទ្របានបង្កើនពី ៣ ដល់ ១២ ដោយធ្វើការច្របាច់បញ្ចូលគ្នាអោយស្ថិតនៅក្រោមឆ័ត្រនៃសហភាពសហគមន៍កសិកម្ម។ យើងកត់សំគាល់ឃើញពីការវិវឌ្ឍនូវផ្នែកអភិបាលកិច្ចក្នុងចំនោមសហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់ មានការប្រសើរឡើងជាងមុន ដែលចំនុចនេះធ្វើអោយពួកគាត់អាចដើរតួនាទីសកម្មដូចដែលមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមគាត់។ បន្ថែមលើសហ្នឹងទៀតក៏មានការកើនឡើងនូវសមាជិកយ៉ាងហោចណាស់ ១៥%ជារៀងរាល់ឆ្នាំ ដែលជាកត្តាជម្រុញអោយមានការបង្កើននូវជំនួញលើសពី១ក្នុងសហគមន៍កសិកម្ម ៧នៃចំនួនសរុប ១២។ ហើយអ្វីដែលយើងមានការអបអរថែមទៀតនោះគឺ ២/៣នៃជួរថ្នាក់ដឹកនាំរបស់សហគមន៍កសិកម្មមានការយល់ច្បាស់អំពីគោលការណ៍ នៃដំណើរការសហគមន៍កសិកម្មក៏ដូចជាការចាត់ចែងជំនួញដោយពួកគាត់អាចចាត់ចែងបានដោយខ្លួនឯងបានដើម្បីចែករម្លែកការយល់ដឹងទាំងនេះបន្តទៅដល់សមាជិករបស់ខ្លួនធ្វើអោយមានការកែប្រែនូវការអនុវត្តដែលមិនត្រឹមត្រូវពីមុនអោយកាន់តែប្រសើរឡើង។
- យើងក៏បានសង្កេតឃើញថា យើងងពិតជាអាចជួយដល់ប្រជាកសិករធ្វើការកែប្រែស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់ដោយធ្វើការការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសេដ្ឋកិច្ចរបស់ប្រជាកសិករ ហើយនឹងអង្គការមូលដ្ឋានរបស់ពួកគាត់។ តាមរយៈគម្រោងនេះយើងធ្វើការយ៉ាងជិតស្និតដោយផ្ទាល់ជាមួយសហគមន៍កសិកម្មចំនួន៣ ក្នុងការអភិវឌ្ឍសមត្ថភាពផ្នែកសេវាកម្មនិងអភិបាលកិច្ច។ ហើយរហូតមកដល់ពេលនេះចំនួនសហគមន៍កសិកម្មដែលបានចុះបញ្ជីរផ្លូវការនៅមន្ទីរកសិកម្មមានការកើនឡើងដល់ ៤៥សហគមន៍ហើយ។ នេះគឺជាកំនើនសមិទ្ធិផលដែលយើងមិនបានរំពឹងទុកដែលវាពិតជាបានកើតឡើងតាមរយះការចូលរួមរបស់គម្រោង ជម្រុញចលនាសហគមន៍កសិកម្មហើយនិងសេវាកម្មនៅក្នុងខេត្តសៀមរាប។ ដូច្នេះយើងជឿជាក់ថាកំនើននៃអង្គការមហាជនពិតជាអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជម្រុញការអភិវឌ្ឍនិងឆ្លើយតបទៅនឹងបញ្ហារបស់ប្រជាកសិករដែលនៅកៀកសហគមន៍កាន់តែមានប្រសិទ្ធិភាព។

<u>គម្រោងទី២</u>

| គោលបំណងគំរោង | លទ្ធផលរំពឹងទុក |
| --- | --- |
| **គោលបំណងជាយុទ្ធសាស្ត្រទី១៖** នៅបំណាច់ឆ្នាំ២០១៧សន្តិសុខស្បៀងកសិករខ្នាតតូចចំនួន៤,៨៣៩នាក់/ស្ត្រី២,៣៣២នាក់ ក្នុងភូមិគោលដៅ ចំនួន២៣ ក្នុងឃុំចំនួន៦និង៤ស្រុកត្រូវបានកែលំអរជីវភាពរស់នៅអោយប្រសើរឡើងជាងមុន។ | **លទ្ធផល.១.១:**កសិករខ្នាតតូច ទាំងស្ត្រី និងបុរស ចំនួន ៤០១ នាក់ក្នុងនោះ មានស្ត្រីចំនួន៣០១នាក់ ក្នុងឃុំចំនួន៣ នៃខេត្តឧត្តរមានជ័យទទួលបានការ រស់នៅប្រសើរ ឡើង តាមរយៈការគ្រប់គ្រងលើក្រុមសន្សំ ធនាគាស្រូវ កសិករ គំរូ និងបង្កើនសម្ថភាពសហគមន៍ដើម្បីអោយមានភាពធន និងគ្រោះមហន្តរាយនិងស្វែងរកការគាំទ្រធនធានសេវាកម្មនិងបញ្ហាកសិកម្ម ត្រូវដោះស្រាយ ដោយមន្ទីរកសិកម្ម ឆ្លើយតបនឹងកសិកម្មនិរន្តរភាពដែលធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ |
| | **លទ្ធផល.១.២:**.៦០%នៃសមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប ៤,៨៣៩នាក់ស្ត្រី/២,៣៣២នាក់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១៣ ធ្វើការ គ្រប់គ្រងថៃរក្សា និងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តភាព។ |
| | **លទ្ធផល.១.៣:**.ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដីសម្បទានសេដ្ឋកិច្ចចំនួន ២២១គ្រួសា(១០៩០ហិកតា)ដែលមិនទាន់មានការដោះស្រាយអាចស្វែងរកការគាំទ្រពីរដ្ឋាភិបាលនិងដំណោះស្រាយសមស្របដោយសន្តិវិធី។ |
| | **លទ្ធផល.១.៤:** ប្រជាពលរដ្ឋដែលរងផលប៉ះពាល់៣៧៣គ្រួសារពីក្រុមហ៊ុន Synohydro នឹងមានសម្ថភាពយល់ដឹងពីសិទ្ធិនានារបស់ខ្លួនដែលមានចែងក្នុង ច្បាប់ អាចធ្វើសកម្មភាពស្របច្បាប់ស្វែងរកការគាំទ្រពីរដ្ឋាភិបាលដើម្បី ទទួលបានដំណោះស្រាយដោយសន្តិវិធី។ |
| **គោលបំណងជាយុទ្ធសាស្ត្រទី២៖** នៅបំណាច់ឆ្នាំ ២០១៧ កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ស្ថិតនៅក្នុងឃុំចំនួនបីទទួលបានការអប់រំនៅថ្នាក់មូលដ្ឋានត្រឹមថ្នាក់ទី៦ប្រសើរជាងមុន។ | **លទ្ធផលទី២.១៖** កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ នៃឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ទទួលបានការសិក្សា បរិយាកាសនៃការសិក្សាប្រសើរជាងមុន តាមរយៈ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។ |
| | **លទ្ធផលទី២.២:** គណៈកម្មការទ្រទ្រង់សាលាទាំង២០សាលា បានអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងសាលារៀនប្រសើរជាងមុន ហើយប្រជាជន រួមទាំងកុមារចំនួន៧០០នាក់/ស្ត្រី៤០០នាក់ បានយល់ដឹងពីពីការលើកកំពស់ សិទ្ធិក្នុងសាលារៀន(PRS)។ |
| **គោលបំណងជាយុទ្ធសាស្ត្រទី៣៖** នៅបំណាច់ឆ្នាំ ២០១៧ ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ រួមទាំងសមា | **លទ្ធផល.៣.១:**ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ និងក្រុមប្រឹក្សាឃុំដែលទទួលបន្ទុក(គកនក)៦នាក់ក្នុងឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់បានប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍ភូមិឃុំរបស់ពួកគាត់ |

| | |
|---|---|
| ជិកសហគមន៍២០ភូមិ និងក្រុមប្រឹក្សាឃុំ នៅក្នុងឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ នៃខេត្តឧត្តរមានជ័យ ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ | ។<br>**លទ្ធផល.៣.២**:សមាជិកសហគមន៍ចំនួន៤០០នាក់/ស្ត្រី៣០០នាក់ បានយល់ដឹងពីតួនាទីយេនឌ័រ និងតួនាទីភេទ។ |

**សន្តិសុខស្បៀង៖** ក្រុមកសិករគំរូ ៩ភូមិ មានភូមិ គោកខ្ពស់ ភូមិគាប ភូមិឈើស្លាប់ និងភូមិអូរទេង បានយល់ពីការផលិតមេជីធម្មជាតិ ការផលិតជីកំប៉ុស្តគោក ការបំបែកមេជីអ៊ីអិម និងថ្នាំពុលធម្មជាតិសំរាប់ដំណាំបន្លែ។ ភូមិចំនួន៣គឺភូមិខ្ញុំ ភូមិតាម៉ាន និងភូមិត្រពាំងវែង ស្ថិតនៅក្នុងសង្កាត់កូនគ្រៀល ត្រូវបានកែសម្រួលលើក្រុមសន្សំ ពីរចនាសម្ព័ន្ធ និងលក្ខន្តិកៈ ដែលបានទទួលស្គាល់ពីមេឃុំ។ លក្ខន្តិកៈ ធនាគារស្រូវ៨ និងក្រុមសន្សំប្រាក់២១ក្រុម ពីការគ្រប់គ្រង តួនាទីរបស់គណៈកម្មការ។ ការខ្ចីសង ការដាក់ប្រាកសន្សំ ស្ថិតក្នុង២១ ត្រូវបានពង្រឹងបន្ថែម ដោយមានសមាជិកចូលរួមចំនួន១០១០នាក់ស្រី៨០៦នាក់។ មានការជួសជុលទ្វាជង្រុកស្រូវ ចំនួន៦កន្លែងនៅភូមិបាក់នឹម អូរទេង ឈើស្លាប់ សំបូរមាស ត្នោត ឆ្អើប និងផ្លាកសញ្ញាបាន៣ភូមិ នៅភូមិ អូរទេង ឈើស្លាប់ និងត្នោត ដែលមានអ្នកចូលរួមធ្វើចំនួន២៤នាក់។ ជង្រុកស្រូវនៅភូមិនេះ កំពុងតែដាក់ទុករក្សាស្រូវសម្រាប់សហគមន៍។

**ការគ្រប់គ្រងធនធានធម្មជាតិ៖** គណៈកម្មការ អនុគណៈកម្មការ និងសមាជិកសហគមន៍ព្រៃឈើ មានការចូលរួមទុបស្កាត់បទល្មើសក្នុងព្រៃសហគមន៍ចំនួន៧មានសមាជិកសហគមន៍ចូលរួម១០១នាក់។ សហគមន៍ទាំងអស់ខាងលើបានដាក់របាយការណ៏ជូនដល់រដ្ឋបាលព្រៃឈើ។ បទល្មើសព្រៃឈើនៅតែកើតមានឡើង ជាពិសេសនៅពេលយប់មានជនល្មើសលួចចូលទៅកាប់ក្នុងព្រៃសហគមន៍។ ការល្បាតមានការសហការជាមួយ ភូមិ ឃុំ ស្រុក នគរបាលប៉ុស្ត៍ថ្នាក់ឃុំ និងទាហ៊ាន ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។ សហគមន៍បានចុះឃាត់ ជនល្មើសអារឈើក្នុងព្រៃសហគមន៍មានគ្នា២៦នាក់ ធ្វើកិច្ចសន្យា និងឃាត់បានឈើ៥៥ក្រប ដកហូតរណាយន្ត៨គ្រឿង ឈើធ្នង់ស្រស់៨ដើម។ ការប្រជុំបណ្តាញមានការចូលរួមពីប្រធាន និងតំណាងគណៈកម្មការសហគមន៍ព្រៃឈើទាំង១២ចំនួន១៦នាក់/ស្រី២នាក់ នៅពេលប្រជុំម្តងៗ ពួកគាត់បានលើកឡើងពីបញ្ហាដែលកើតមានឡើងរបស់សហគមន៍ និងការរាយការណ៏ជូនរដ្ឋបាលព្រៃឈើពុំមានដំណោះស្រាយ។ ចុងបញ្ចប់សហគមន៍ទាំង១២បានរៀបចំផែនការបន្តរបស់ខ្លួនទៅតាមសហគមន៍នីមួយៗ។សហគមន៍ភ្នំដងរែកសម្រែក ព្រៃស្រស់បានចុះធ្វើកិច្ចសន្យាដល់ប្រជាពល់រដ្ឋដែលយកដីសហគមន៍ប្រើប្រាស់ផ្ទាល់ខ្លួន នៅក្នុងចំណុចត្រពាំងត្រាវបានចំនួន១៥គ្រួសារដោយសរុបផ្ទៃដីចំនួន303,600ម៉ែត្រការេស្មើនិង30, 36ហិចតា ដើម្បីបញ្ឈប់ការកាប់បន្តទៀត ដោយមានកិច្ចសហការជាមួយលោកអភិបាលស្រុករង មេឃុំ មេភូមិ និងគណៈកម្មការសហគមន៍ សរុបទាំងអស់មាន១៦នាក់ស្រី១នាក់។ របាយការនៃការស្រាវជ្រាវមួយត្រូវបានសរសេរបង្កើតឡើងពីផលប៉ះពាល់ដោយសារការសាងសង់ទំបន់ទឹក Synohydro។ តំណាងអ្នករងផលប៉ះពាល់ដីធ្លីចំនួន៦នាក់ស្រី១នាក់បានរៀបចំកិច្ចប្រជុំដើម្បីពិភាក្សាអំពីការឡើងមកជួបអាជ្ញាធរ សង្កាត់ ក្រុង ខេត្ត ដើម្បីរកដំណោះស្រាយការកាន់កាប់ដីធ្លីនៅក្នុងភូមិចំនួន៥ គឺមានភូមិ បុស្ស ភូមិបាក់និម ភូមិអូរបាត់មាន់ ភូមិតាម៉ាននិង ភូមិស្រះព្រិច។ អង្គការកែប្រែសហគមន៍ បានយកបញ្ហានេះធ្វើការចូលក្នុងបណ្តាញព្រៃឈើនិងREDD+ជាមួយ NGOs forum ផងដែរ។

**ការអប់រំ៖** ឆ្នាំ ២០១៦ អង្គការស៊ីធីអូ បានធ្វើការប្រមូលសារ សម្រេចបានប្រមាណ ១០០ % បើធៀបនិង សុច្ចនករ ដែលមានចែងនៅក្នុងផែនការប្រចាំឆ្នាំ២០១៦សរុបទាំងអស់១៨ភូមិ។ បុគ្គលិករបស់អង្គការ ស៊ី ធី អូ បានចុះអនុវត្តន៍ទៅតាមភូមិគោលដៅដោយមានការសហការជាមួយមេភូមិ និងអ្នកគ្រូស្ម័គ្រចិត្ត២៥នាក់ នៅតាមភូមិនិមួយៗដើម្បីធ្វើការប្រមូលសារ

ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមសរុប: 581នាក់ ស្រី 338នាក់។ អង្គការ ស៊ី ធី អូ បានរៀបចំការប្រកួតប្រជែងប្រលងគំនូរកុមារ នៅមន្ទីរផែនការខេត្ត ដែលមានអ្នកចូលរួមសរុប ៥៣ នាក់ស្រី ៣៥ នាក់ ដែលមានកុមារចូលរួមពី ១៨ភូមិ គឺកុមារបានទាំងអស់បានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការគូរគំនូរ និងផលប៉ះពាល់នៃការបាត់បង់ព្រៃឈើ។ ជាពិសេសកុមារបានបញ្ចេញស្នាដៃរបស់ខ្លួន និងលើកទឹកចិត្តអោយកុមារចង់ចូលរួមក្នុងការគូរសារ។ ក្នុងកម្មវិធីនេះ មានការលើកទឹកចិត្តកុមារទាំងអស់ ដែលបានលេខ១ ដល់លេខ៣ ទទួលបានកង់១ ការបូប១ សៀវភៅ៣ក្បាល ប៊ិច១ដើម ចំពោះអ្នកលេខ៤ ចុះក្រោមទទួលបាន ការបូប១ សៀវភៅ២ក្បាល ប៊ិច១គូរ។ សម្ភារៈសិក្សាទាំងអស់នេះដើម្បីជំរុញអោយកុមារតាំងចិត្តក្នុងការសិក្សា ជាពិសេសកុមារដែលបោះបង់ការសិក្សាអោយពួកគាត់ចងចូលចូលរៀនវិញ ក្រោយពីទទួលបានសម្ភារៈសិក្សាទាំងនេះ។ ស៊ីធីអូបានសហការណ៍ ជាមួយនាយកសាលារៀបចំធ្វើបំនិនជីវិត នៅតាមសាលារៀនចំនួន06 ដែលមានអ្នកចូលរួមសរុប ១៥៨នាក់ ស្រី ៧៧នាក់។ កុមារដែលលចូលរួមបានយល់ដឹងពីរការដាំបន្លែ វិធីសាស្ត្រនៃការលាយជី និងរបៀបនៃការថែទាំបន្លែ។ ជាពិសេសពី របៀបនៃការកែច្នៃរបស់សំណល់មកធ្វើឲ្យមានប្រយោជន៍ដូចជាយកសំបកកង់ឡាន ឬកង់ម៉ូតូ ការ៉ុង និងសំបកដប មកដាំបន្លែដោយមិនបាច់ចំណាយដីសម្រាប់ដាំច្រើន ឬទឹកច្រើនសម្រាប់ស្រោច។ ហើយពួកគាត់អាចយកគំនិតនេះទៅកែច្នៃដាំបន្លែនៅផ្ទះដោយខ្លួនឯងបាន ពួកគាត់អាចយកគំនិតទាំងនេះទៅបង្ហាញដល់ឪពុកម្តាយ បងប្អូន និងមិត្តភក្តិរបស់គាត់ផ្សេងទៀតដើម្បីចេះដាំបន្លែ។ ទិវាកុមារអន្តរជាតិវាទិកានេះធ្វើឡើងបីឃុំ មានសំពោង បន្សាយរាក់ គោកខ្ពស់ ដោយមានអ្នកចូលរួមសរុបចំនួន១.៧២១នាក់ ស្រី១.០១១នាក់។ អ្នកចូលរួមទាំងអស់ ជាពិសេសកុមារ បានដឹងពីប្រវត្តិទិវាកុមារអន្តរជាតិ ១មិថុនា ដ៏មានអត្ថន័យ បង្កប់នូវភាពឈឺចាប់របស់កុមារពីអតីត ដាស់អារម្មណ៍សិស្សានុសិស្សឲ្យមានភាពក្លាហាន ហានបញ្ចេញនូវអ្វីដែលខ្លួនមាន អោយអស់ពីសម្ថតភាព ហើយមាតាបិតាសិស្សបានយល់ច្បាស់ពីការចូលរួមការពារ និងថៃទាំកុមារ ពួកគាត់មាឱកាសក្នុងការសួរការិយាល័យអប់រំ នាយកសាលា ពីការរៀន និងការបង្រៀន និងការអភិវឌ្ឍន៍សាលារៀនកន្លងមក។ ក្នុងនោះដែរសិស្សានុសិស្សបាន ស្ម័គ្រចិត្តឡើងបេះដូងប្រជាធិបតេយ្យ ដើម្បីឆ្លើយសំនួរយករង្វាន់ដូចជា សៀវភៅ ប៊ិច ច្រៀងចម្រៀង បង្ហាញម៉ូត ដើម្បីឲ្យកម្មវិធីមានភាពសប្បាយបន្ថែមទៀត។ ស៊ីធីអូ បានរៀបចំការផ្សព្វផ្សាយពីសិទ្ធិទាំង១០នៅក្នុងសសាលារៀន នៅមន្ទីរផែនការខេត្តឧត្តរមានជ័យ មានអ្នកចូលរួមសរុប៥៣នាក់ស្រី៣៥នាក់ ដែលមានកុមារចូលរួមពី១៨ភូមិ។ បានធ្វើការរៀបចំប្រជុំជាមួយសមាជិកគណៈកម្មការ និងអាជ្ញាធរភូមិដើម្បីធ្វើការពិភាក្សារៀបចំបង្កើតអោយមានគោលការណ៍យេនឌ័រនៅក្នុងធនាគារស្រូវ និងក្រុមសន្សំប្រាក់ចំនួន២០ភូមិ ទទួលស្គាល់ពីមេឃុំរួចហើយ។ អ្នកចូលរួមចំនួន523 នាក់ក្នុងនោះមានស្ត្រីចំនួន424នាក់ អ្នកចូលរួមទាំងបុរសស្ត្រីបានធ្វើការឯកភាពគ្នាក្នុងការបង្កើតអោយមានគោលការណ៍យេនឌ័រនេះឡើង។ ពួកគាត់បានធ្វើការបញ្ជាក់ថាពេលមានគោលការណ៍នេះហើយ វាអាចអោយក្នុងក្រុមសន្សំធនាគារស្រូវទាំងបុរសស្ត្រី ធ្វើការសំរេចចិត្តដោយមានសមភាព និងសមធម៌នៅក្នុងសង្គមឬនៅក្នុងក្រុមគ្រួសារ គ្មានអំពើហឹង្សាកើតឡើងជាពិសេសពេលមានគោលការណ៍នេះ និងធ្វើអោយបុរសស្ត្រីមានសិទ្ធិក្នុងការចូលរួមបញ្ចេញមតិយោបល់បានស្មើគ្នា។

**ការពង្រឹងសម្ថភាពបុគ្គលិកៈ** បុគ្គលិកទទួលបន្ទុកហិរញ្ញវត្ថុ និងអ្នកសម្របសម្រួលកម្មវិធីបានបានចូលរួមវគ្គសិក្ខាសាលាជាមួយអង្គការAACពីរបាយការណ៍ ទម្រង់របាយការណ៍ផ្សេងៗទាក់ទងនឹងគណនេយ្យអោយកាន់តែច្បាស់លាស់ជាងមុន។ មានការបណ្តុះបណ្តាលពីការដាំដំឡូងមីប្រកបដោយនិរន្តរភាពដែលមានការបណ្តុះបណ្តាលដោយអង្គការGIZ។ ជំនួយការគម្រោងម្នាក់គឺលោកបានលាឈប់ពីអង្គការCTOនៅខែវិច្ឆិកាឆ្នាំ២០១៦ ដោយសាគាត់ប្រឡងជាប់ក្នុងក្របខណ្ឌរដ្ឋនៅមន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ។

**<u>លទ្ធផលទី ១.១៖</u>** កសិករខ្នាតតូច ទាំងស្ត្រីនិងបុរសចំនួន ៩០១គ្រួសារក្នុងនោះមានស្ត្រីចំនួន៣០១នាក់ ក្នុងឃុំចំនួន៣ នៃខេត្តឧត្តរមានជ័យទទួលបានការរស់នៅប្រសើរឡើងតាមរយៈការគ្រប់គ្រងលើក្រុមសន្សំ ធនាគាស្រូវ និងបង្កើនសម្ថភាពសហគមន៍ ដើម្បីអោយមានភាពធននឹងគ្រោះមហន្តរាយ និងស្វែងរកការគាំទ្រធនធាន សេវាកម្ម និងបញ្ហាកសិកម្មត្រូវដោះស្រាយដោយមន្ទីរកសិកម្មឆ្លើយតបនឹង កសិកម្មនិរន្តរភាពដែលធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ។

*១.១.១-ពង្រឹងលើក្រុមកសិករគំរូ និងកសិករពង្រីកលើដំណាំស្រូវនឹងបន្លែលើតួនាទី ការទទួលខុសត្រូវ និងតាមដាន*

មានការបើកវគ្គបណ្ដុះបណ្ដាលពីរវគ្គនៅថ្នាក់ឃុំស្ដីពី ការពង្រឹងលើក្រុមកសិករគំរូ ក្នុងការផលិតមេជីធម្មជាតិ ការផលិតជីកំប៉ុស្តគោក ការបំបែកមេជីអ៊ី អ៊ិមនិងថ្នាំពុលធម្មជាតិសំរាប់ដំណាំបន្លែរនៅឃុំគោខ្ពស់។ ដោយមានការចូលរួម ពីកសិករចំនួន ៤ភូមិ មានភូមិ គោកខ្ពស់ ភូមិគាប ភូមិឈើស្លាប់ និងភូមិអូរទេង។ មានអ្នកចូលរួមសរុបចំនួន៥០នាក់ ស្រីចំនួន២៨នាក់ កសិករភាគច្រើនយល់ដឹងពីរបៀបផលិត និងប្រើប្រាស់ជី និងថ្នាំពុលធម្មជាតិ អ្នកចូលរួមទាំងអស់បានអនុវត្តជាក់ស្ដែង និងមើលពីរបៀបធ្វើមេជី និងថ្នាំពុល ទទួលបានមេជីអ៊ីអឹមមួយធុង ជីកំប៉ុស្តទឹកមួយធុង និងថ្នាំពុលធម្មជាតិមួយធុង។ កសិករមានជំនឿចិត្តគាត់ពិតជាអាចធ្វើបានបន្ទាប់ពីចប់វគ្គបណ្ដុះបណ្ដាលនេះ។ ពួកគាត់មានផែនកាក្នុងការទៅអនុវត្តផ្ទាល់ពីការប្រើប្រាស់ មេជី ជីកំប៉ុស្តទឹក និងថ្នាំពុលធម្មជាតិដែលបានផលិតនោះ នៅវគ្គបន្តទៀត គាត់នឹងចូលរួមនៅវគ្គបណ្ដុះបណ្ដាលមួយលើកក្រោយទៀត ដែលទាក់ទងនឹងមេរៀនពីមុន និងមេរៀនថ្មីៗទៀត កសិកថានឹងខំប្រឹងប្រែងដាំដំណាំ នៅពេលដែលទីតាំងគាត់មានទឹកគ្រប់គ្រាន់សំរាប់ដាំដំណាំ។ កសិករនឹងប្រើប្រាស់ជី និងថ្នាំពុលដែលផ្សំពីធម្មជាតិទៅលើដំណាំ ដើម្បីសុខភាពអ្នកប្រើប្រាស់ អ្នកបរិភោគ និងបរិស្ថាន។

*១.១.២-ផ្សព្វផ្សាយ និងតាមដានពីគោលការណ៍កសិកម្មនិរន្តរភាពដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ*

បុគ្គលិក CTO និងតំណាងកសិករគំរូបានធ្វើការផ្សព្វផ្សាយដល់កសិករអោយពួកគាត់បានយល់ដឹង អំពីការដាំដំណាំដែលធន់និងកំដៅថ្ងៃ ហើយប្រើប្រាស់ទិកតិចព្រមទាំងធ្វើការជ្រើសរើសគ្រាបពូជ និងអោយពួកគាត់ចេះធ្វើការពិភាក្សាគ្នាលើការដាំដុះសមស្រប តាមតំរូវការទីផ្សារហើយលក់បានថ្លៃ ជាពិសេសទៅទៀត ក្នុងការផលិតជីកំប៉ុស្តិនិងថ្នាំពីរុកជាតិក្នុងការដាក់ដំណាំដោយគ្មានប៉ះពាល់សុខភាពមនុស្ស។ ការចុះធ្វើការផ្សព្វផ្សាយមានចំនួន១០ភូមិ គឺភូមិ គោកខ្ពស់ ភូមិប្រិយ៍ ភូមិរំដួលវាសនា ភូមិអូរឬស្សី ភូមិពោធិវង្ស ភូមិព្រៃទទឹង ភូមិឈើស្លាប់ ភូមិគាប ភូមិអូរទេង និងភូមិសំបូរមាស ដោយមានអ្នកចូលរួមចំនួន575នាក់ស្រី445នាក់។ អ្នកចូលរួមបានយល់ដឹងពីអំពីរបៀបការជ្រើសរើសគ្រាប់ពូជដាំនៅរដូវប្រាំងដែលធន់នឹងកំដៅថ្ងៃហើយប្រើប្រាស់ទឹកតិច ផលប៉ះពាល់ការប្រើប្រាស់ជីគីមីនិងថ្នាំពុល ផលិតជីកុំប៉ុស្តិនិងថ្នាំសំម្លាប់សត្វល្អិត កាត់បន្ថយការចំណាយលុយកាត់ក្នុងគ្រួសារ របៀបទុកដាក់ពូជដាំបន្តកន្លែងមានសុវត្ថិភាព។ អ្នកចូលរួមបានរៀបចំផែនការដាំដុះអោយត្រូវតាមតំរូវការទីផ្សារសមស្របអចិជនជាពិសេសលក់ផលិតផលបានថ្លៃ និងពិភាក្សាក្រុមការបែងចែកមុខដំណាំខុសៗគ្នាងាយស្រួលក្នុងការលក់។ បានធ្វើការសភាសន៍ជាមួយគ្រួសារកសិករចំនួន១០គ្រួសារក្នុងពីរភូមិដើម្បីបញ្ជាក់ ពីមុនចាប់ផ្ដើមនិងក្រោយអនុវត្តនិងធ្វើការប្រៀបធៀបគ្នាពីភាពរីកចំរើនរបស់គ្រួសារនិមួយៗ។ អ្នកចូលរួមទាំអស់គ្នាបានពិភាក្សានិងចែករំលែកបទពិសោធន៍អំពីការដាំដំណាំផ្លាស់ប្ដូរដើម្បីថែរក្សាគុណភាពដីល្អបានយូរ។

*១.១.៣-បង្កើតក្រុមសន្សំថ្មី ៣ក្រុម ដល់ជនងាយរងគ្រោះដីធ្លី និងពង្រឹងវចនាសម្ព័ន្ធក្រុម*

បានប្រជុំភូមិចំនួន៣ភូមិគឺភូមិខ្ញុំ ភូមិតាម៉ាន និងភូមិត្រពាំងវែង ស្ថិតនៅក្នុងសង្កាត់កូនគ្រៀល ក្រុងសំរោងខេត្តឧត្តរមានជ័យ ដើម្បីរៀបចំបង្កើតអោយមានក្រុមសន្សំ ការរៀបចំរចនាសម្ព័ន្ធ គោលការណ៍របស់ក្រុម ជាពិសេសជនងាយរងគ្រោះដីធ្លី ដោយមានការគាំទ្រពីអាជ្ញាធរភូមិ និងសង្កាត់។ ដោយមានអ្នកចូលរួមប្រជុំចំនួន៨១នាក់ស្រី៥៩នាក់។ នៅក្នុងភូមិនោះមានកម្មវិធីចាស់ដូចជាៈ សន្សំប្រាក់ កម្មវធីគោ ជ្រូក ថវិកាទាំងនោះមានការជួយគាំទ្រពីអង្គការមុនៗមិនសូវដំណើរការល្អ។ ភូមិខ្ញុំថវិកាមានចំនួន(១,៥៧០$) ភូមិតាម៉ានប្រាក់សន្សំមានចំនួន៩,៨៨៤,៥០០៛ ប្រាក់គោមានចំនួន ៥,០០០,០០០៛ សរុបថវិកាចំនួន(១៤,៨៨៤,៥០០៛) ភូមិត្រពាំងវែង មិនបានទទួលទិន្នន័យបានទេ។ ក្នុងនោះមានរៀបចំផែនការអនុវត្តបន្តជាមួយគ្នាដូចជា រៀបចំរចនាសម្ព័ន្ធថ្មីឡើងវិញ រួមទាំងគោលការណ៍របស់ក្រុមផងដែរ។ រៀបចំបញ្ជីស្នាមរបស់ក្រុមនិងកូនសៀវភៅរបស់សមាជិកម្នាក់ៗ ជួបពិភាក្សាជាមួយគណៈកម្មការចាស់អំពីថវិកា ដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរដើម្បីអោយបុគ្គលិកអង្គការមុនយកថវិកាមកសងសហគមន៍វិញ ប្រជុំជាមួយសមាជិកក្រុមអោយបានទៀងទាត់រៀងរាល់ខែ។

*១.១.៤-ចងក្រង លក្ខន្តិកៈដើម្បីអោយមានការទទួលស្គាល់ពីភូមិ ឃុំ*

CTO បានរៀបចំកិច្ចប្រជុំនៅភូមិត្រពាំងវែង តាម៉ាន ខ្ញុំ ដើម្បីកែសម្រួលរចនាសម្ព័ន្ធ លក្ខន្តិកៈរបស់ក្រុមដោយមានការ ចូលរួមពីអាជ្ញាធរ ភូមិ និងប្រជាជនទូទាំងភូមិចំនួន២៩នាក់ស្រី១៨នាក់។ អង្គប្រជុំបានសំរេច និងឯកភាពរៀបចំបង្កើត ក្រុមសន្សំថ្មីចំនួនមួយក្រុម ដោយមានសមាជិក១១នាក់ និងធ្វើការជ្រើសរើសតំណាងក្រុមចំនួន៥រូប ក្នុងនោះមានប្រធាន អនុប្រធាន បេឡា លេខា និងសមាជិកក្រុមធ្វើការការបោះឆ្នោតជាសំងាត់។ ភូមិនេះមានប្រាក់ដើមដែលអង្គការUNDPដាក់អោយចំនួន៧១០$=២,៨៤០,០០០៛ គណកម្មការដកចំណាយអស់៦៩,៥០០៛ ថវិកាដែលនៅសល់ ទាំងអស់២,៧៧០,៥០០៛ ដើមមានចំនួន ២,៧៧០,៥០០៛ ការចំនួន៣៧,៨០០៛។ ក្នុងនោះមានថវិកាគោចំនួនចំនួន៥០០$ =២,០០០,០០០៛ កាត់ខាតគោងាប់ ៥០% = ៥០០,០០០៛ នៅសល់ជាក់ស្ដែងមានចំនួន១,៥០០,០០០៛ = ៣៧៥$ សរុបថវិកាទាំងពីរសកម្មភាពសល់ចំនួន ៤,២៧០,៥០០៛។

*១.១.៥-ពង្រឹងលើលក្ខន្តិកៈ ធនាគាស្រូវ និងសន្សំ*

ការពង្រឹងលក្ខន្តិកៈ ធនាគារស្រូវ៨ និងក្រុមសន្សំប្រាក់២១ក្រុម ពីការគ្រប់គ្រង តួនាទីរបស់គណៈកម្មការ ការខ្ចីសង ការដាក់ប្រាកសន្សំស្ថិតក្នុង២១ភូមិ។ ដោយមានសមាជិកចូលរួមចំនួន១០១០នាក់ស្រី៨០៦នាក់ ក្នុងសមាជិកចូលថ្មីចំនួន៤នាក់បន្ថែម។ គណៈកម្មការ និងសមាជិកបានយល់បន្ថែមពីលក្ខន្តិកៈរបស់ក្រុម និងធ្វើការផ្សព្វផ្សាយទៅដល់ អ្នកភូមិបន្តពីសារៈប្រយោជន៍នៃការបង្កើតក្រុមសន្សំដើម្បីបង្កើនទុននៅក្នុងភូមិ កាត់ការខ្ចីពីខាងក្រៅមានការប្រាក់ខ្ពស់។ បានធ្វើការពង្រឹង រចនាសម្ព័ន្ធធនាគារស្រូវនៅភូមិអូរទេងដោយមាន ការឯកភាពជ្រើសរើសគណៈកម្មការជាបុរសបន្ថែមចំនួន២នាក់ និងធ្វើការកំណត់ការ ចែកស្រូវអោយទៅតាមផែនការ។ ធនាគាស្រូវ និងប្រាក់សន្សំមានការកើនឡើងជាលំដាប់។

*១.១.៦-តាមដានផ្ទះបញ្ចាំងដល់គណៈកម្មការក្រុមសន្សំ ដើម្បីធ្វើការកែតំរូវទាំង២១ក្រុម និងក្រុមធនាគារស្រូវ៨ក្រុម អោយមាននិរន្តរភាពរៀងរាល់៣ ខែម្ដង*

បុគ្គលិកចុះធ្វើការតាមដានផ្ទះបញ្ចាំងដល់គណៈកម្មការសន្សំ២១ និងធនាគារស្រូវ៨ បានចំនួន២១ភូមិ ដោយមានសមាជិកចូលរួមចំនួន៣៣៦នាក់ស្រី២៧២នាក់។ គណៈកម្មការបានយល់កាន់តែច្បាស់អំពីការចុះក្រុម និងកូនសៀវភៅរបស់សមាជិកអោយបានរៀងរាល់ខែតាមក្រុមនិមួយៗ-ពង្រឹងលើលក្ខន្តិកៈនិងគោលការណ៍របស់ស្ដីពីការដាក់សន្សំអោយទៀងទាត់

គណៈកម្មការបានយល់ដឹងពីការចុះបញ្ជីស្នាមការគ្រប់គ្រងសមាជិក និងចរិការបស់ក្រុមច្បាស់លាស់ជាងមុន សមាជិកក្នុងក្រុមបានចេះជួយរំលែកទុកលំបាករបស់សមាជិកនៅពេលមានបញ្ហា។

*១.១.៧-ប្រជុំឆ្លុះបញ្ចាំង ៣ខែម្តង(ក្រុមសន្សំ កសិករគំរូ និងធនាគាស្រូវ)*

ការឆ្លុះបញ្ចាំងប្រចាំឆ្នាំដល់គណៈកម្មការសន្សំ២១ក្រុម និងធនាគារស្រូវ ៨បានចំនួន២១ភូមិដោយមាសមាជិកចូល រួមចំនួន ៥៣០នាក់ស្រី៣៧៨នាក់ សមាជិកបានយល់ពីគោលការណ៍សន្សំ គោលការធនាគារស្រូវ និងគោលការយេនឌ័រ យល់ដឹងពីសារប្រយោជន៍នៃការចូលរួមសន្សំជួយគ្នានៅក្នុងក្រុម និងការចូលប្រាក់សង្គ្រោះសំរាប់ជួយសមាជិកក្នុងក្រុមមាន បញ្ហាបន្ទាន់ដូចជា ឈឺ ឬក៏ស្លាប់ ផ្តល់អោយទៅតាមគោលការណ៍របស់ក្រុមដែលបានឯកភាពពីសមាជិកក្រុម។ ការសន្សំប្រាក់របស់សមាជិកបានកើនឡើងនៅតាមក្រុមនិមួយៗ ពី១លានទៅ៣លានរៀល បានកើនក្រុមថ្មីចំនួន២ក្រុមបន្ថែមគឺ ភូមិឈូក និងភូមិអូរទេង ។

*១.១.៧-ជួសជុលធនាគារស្រូវ៨ និងធ្វើផ្លាកសញ្ញា*

មានការជួសជុលទ្វារជង្រុកស្រូវចំនួន៦កន្លែងនៅភូមិបាក់នឹម អូរទេង ឈើស្លាប់ សំបូរមាស ត្នោត ឆ្អើប និងប្លាកសញ្ញាបាន៣ភូមិ នៅភូមិ អូរទេង ឈើស្លាប់ និងត្នោត ដែលមានអ្នកចូលរួមធ្វើចំនួន២៨នាក់។ ជង្រុកស្រូវនៅភូមិនេះកំពុងតែដាក់ទុករក្សាស្រូវសម្រាប់សហគមន៍។

*១.១.៨-ប្រជុំប្រចាំត្រីមាសបណ្តាញCASNថ្នាក់ខេត្ត*

ការប្រជុំCASNថ្នាក់ខេត្តមានការចូលរួម៨នាក់/ស្រីម្នាក់ បានពិភាក្សាសម្រេចលើលក្ខន្តិកៈរបស់CASN ដែលមាន ទស្សនវិស័យ បេសកកម្ម គុណតម្លៃ គោលដៅរួម គោលបំណង សមាសភាពអ្នកថ្នាក់ដឹកនាំបណ្តាញក្រុមប្រឹក្សាយោបល់ រចនាសម្ពន្ធ័ ក្នុងនោះបានអានពីលក្ខណៈវិនិច្ឆ័យ និងការទទួលខុសត្រូវ របស់សមាសភាពក្នុងបណ្តាញ។ លើសពីនោះក៏បាននិយាយពីយន្តការក្នុងការទំនាក់បណ្តាញ។ លក្ខន្តិកៈត្រូវបានរៀបចំរួច និងចុះហត្ថលេខា ដោយប្រធាន និងក្រុមប្រឹក្សាយោបល់ បានជ្រើសរើសប្រធានបណ្តាញថ្មី ជំនួសប្រធានចាស់។ បណ្តាញបានរៀបចំផែនការបន្តរបស់ខ្លួន ប្រធានបណ្តាញCASNថ្នាក់ជាតិ និង CTO បានធ្វើការបណ្តុះបណ្តាលច្បាប់ព្រៃឈើដល់គណៈកម្មការ និងអនុគណៈម្មការសហគមន៍ព្រៃឈើដែលទើបជាប់ឆ្នោតថ្មីចំនួន២២នាក់ ក្នុងនោះស្ត្រី៣នាក់។ គោលបំនងដើម្បីអ្នកចូលរួមយល់ដឹងពីតួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍ព្រៃឈើ ស្ថាប័ន និងអាជ្ញាធរសមត្ថកិច្ចទទួលខុសត្រូវ កិច្ចព្រមព្រៀងព្រៃសហគមន៍។ អ្នកចូលរួមបានយល់ដឹងពីរដ្ឋបាលព្រៃឈើ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ការហាមឃាត់ប្រមូលផល អនុផលព្រៃឈើ សិទ្ធិប្រើប្រាស់ជាប្រពៃណី និងការគ្រប់គ្រងព្រៃសហគមន៍ និងព្រៃឯកជន បទល្មើសព្រៃឈើ និងទោសប្បញ្ញត្តិ និងអនុក្រិតនៃការបង្កើតសហគមន៍ព្រៃឈើ ដោយលើកឡើងនូវមាត្រាសំខាន់សម្រាប់សហគមន៍បានយល់ដឹងដូចជា តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍ព្រៃឈើ ស្ថាប័ន និងអាជ្ញាធរសមត្ថកិច្ចទទួលខុសត្រូវ កិច្ចព្រមព្រៀងព្រៃសហគមន៍ ។

*១.១.៩-ភ្ជាប់បណ្តាញCASNជាមួយបណ្តាញថ្នាក់ជាតិ*

បណ្តាញថ្នាក់ជាតិ លោក ត្រេន ត្រៃ និងបណ្តាញCASN ៩នាក់ផ្សេងទៀតមកពីខេត្តផ្សេងបានចូលរួមបង្ហាញពីសកម្មភាពពីសារតារបស់បណ្តាញដូចជា ប្រវត្តិ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ គោលដៅរួម គោលបំណង រចនាសម្ពន្ធ័ សកម្មភាពមួយចំនួនរបស់បណ្តាញ ភាពជោគជ័យ មេរៀន និងបទពិសោធន៍ និងបញ្ហាប្រឈម ដល់អង្គការActionaid និងអង្គការដៃគូរមកពីប្រទេសវៀតណាម។

**<u>លទ្ធផលទី ១.២៖</u>** ៦០%នៃសមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប៩,៨៣៩នាក់ស្ត្រី/២,៣៣២នាក់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១៣ ធ្វើការ គ្រប់គ្រងថែរក្សា និងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តភាព។

*១.២.១-គាំទ្រមធ្យោបាយចុះល្បាតបទល្មើសកាប់ឈើខុសច្បាប់នៅក្នុងដែនព្រៃការពាររបស់សហគមន៍*

គណៈកម្មការ អនុគណៈកម្មការ និងសមាជិកសហគមន៍ មានការចូលរួមទុបស្កាត់បទល្មើសក្នុងព្រៃសហគមន៍ចំនួន៧ មានសមាជិកសហគមន៍ចូលរួម១០១នាក់។ សហគមន៍ទាំងអស់ខាងលើបានដាក់របាយការណ៍ជូនដល់រដ្ឋបាលព្រៃឈើ។ បទល្មើសព្រៃឈើនៅតែ កើតមានឡើង ជាពិសេសនៅពេលយប់មានជនល្មើសលួចចូលទៅកាប់ក្នុងព្រៃសហគមន៍។ ការល្បាតមានការសហការជាមួយ ភូមិ ឃុំ ស្រុក នគរបាលប៉ុស្ត៍ថ្នាក់ឃុំ និងទាហ៊ាន ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។ ក្រុមល្បាតបានចុះឃាត់ជនល្មើសអារឈើក្នុងព្រៃសហគមន៍មានគ្នា២៦នាក់ ធ្វើកិច្ចសន្យា និងឃាត់បានឈើ៥៥ក្រប ដកហូតរណាយន្ត ៨គ្រឿង ឈើធ្នង់ស្រស់៨ដើម។ មានការឃាត់ទាហ៊ានកងពល៤២បានឈូសឆាយដីក្នុងព្រៃសហគមន៍ពី៥ទៅ១០ហិកតា។ សហគមន៍ភ្នំដងរែកសម្រែកព្រៃស្រស់បានធ្វើកិច្ចសន្យាជាមួយប្រជាជនដែលមកពីសង្កាត់បន្សាយរាក់ចំនួន១២គ្រួសារដែលចូលមករុករានដីព្រៃខុសច្បាប់ក្នុងព្រៃសហគមន៍ ក្នុងមានមេឃុំ គោកខ្ពស់ ជំទប់ទី១ ប្រធានគណៈកម្មការ សមាជិក នគរបាលប៉ុស្ត៍ ទាហ៊ាន អភិបាលរងស្រុកបន្ទាយអំពិលធ្វើក្រវាត់ព្រំប្រទល់ព្រៃសហគមន៍បានចំនួន៣៦៥៥ម៉ែត្រ។ ដើម្បីធ្វើការទប់ស្កាត់ការកាប់រុករានដីព្រៃសហគមន៍អស់ចំនួន៥០ហិចតា ដោយមានការសាងស្រង់ពោងស័ង្កសី១ខ្នង និងបោះតងក្តៅស៊ូ៩កន្លែង។ ឯកឧត្តមអភិបាលខេត្តបានបញ្ជាក់ថាបញ្ហាទាំងអស់នេះគឺជាបញ្ហាធំនៅក្នុងសហគមន៍លោកនិងរកឱកាសដើម្បីធ្វើការដោះស្រាយទៅលើបញ្ហាទាំងនោះដោយបានឆាប។ គណៈកម្មការសហគមន៍ព្រៃឈើភ្នំដងរែកសម្រែកព្រៃស្រស់បានសហការជាមួយអភិបាលរងក្រុងសំរោង អភិបាលរងស្រុកបន្ទាយអំពិល លោកមេឃុំគោកខ្ពស់លោកចៅសង្កាត់បន្សាយរាក់ មេបញ្ជាការ មេភូមិ បានធ្វើការប្រជុំដោះស្រាយបញ្ហាទៅលើបញ្ហា១០១គ្រួសារ ដែលមកធ្វើការដាំដុះនៅលើដីរបស់សហគមន៍ដោយគ្មានការទទួលសុខពីអាជ្ញាធរណាឡើយ។

*១.២.២-ប្រជុំប្រចាំឆមាសបណ្តាញសហគមន៍ព្រៃឈើទាំង១៣សហគមន៍នៅខេត្តឧត្តរមានជ័យដោះស្រាយពីដីធ្លី និងព្រៃឈើ*

ការប្រជុំបណ្តាញមានការចូលរួមពីប្រធាន និងតំណាងគណៈកម្មការសហគមន៍ព្រៃឈើទាំង១២ចំនួន១៦នាក់/ស្រី២នាក់ នៅពេលប្រជុំម្តងៗ ពួកគាត់បានលើកឡើងពីបញ្ហាដែលកើតមានឡើងរបស់សហគមន៍ និងការរាយការណ៍ជូនរដ្ឋបាលព្រៃឈើពុំមានដំណោះស្រាយ។ ចុងបញ្ចប់សហគមន៍ទាំង១២ បានរៀបចំផែនការបន្តរបស់ខ្លួនទៅតាមសហគមន៍នីមួយៗ។ បានរៀបប្រជុំ បណ្តាញ រៀបចំផែនការយុទ្ធសាស្រ្តថ្មី និងការបង្កើត ហ្វេសប៊ុកសម្រាប់ផ្សព្វផ្សាយពត៌មាន ពីសហគមន៍ព្រៃឈើនៅក្នុងខេត្តឧត្តរមានជ័យ។ សហគមន៍និមួយៗបានចូលរួមចែករំលែកបញ្ហាដល់អង្គប្រជុំទាំងមូល ប្រធានបណ្តាញបានចែករំលែកនូវពត៌មានទៅគ្រប់សហគមន៍ ការបង្កើតហ្វេសប៊ុក និងរបៀបប្រើប្រាស់ត្រូវបានសហគមន៍ចំនួន២យល់ដឹង ប្រធាន និងគណៈកម្មការសហគមន៍ទាំងពីរបានប្តេជ្ញាក្នុងការការពារព្រៃសហគមន៍តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីមួយនេះ។ ពួកគាត់បានយល់ដឹងបន្ថែមពីការថតរូបតាមទូរសព្ទ័ធម្មតា ឬតាមកាមេរ៉ា និងតាមដានទៅលើគណៈកម្មការសហគមន៍ ក្នុងការប្រើប្រាស់ហ្វេសប៊ុករៀបចំ ពាក្យបណ្តឹងទៅក្រសួងកសិកម្ម និងសម្តេចនាយករដ្ឋមន្ត្រីតាមរយៈហ្វេសប៊ុក។ ការបង្កើតហ្វេសប៊ុក និងរបៀបប្រើប្រាស់ដល់គណៈកម្មការសហគមន៍ចំនួន០៧សហគមន៍។ ប្រធានសហគមន៍ព្រៃឈើរតនៈរុក្ខា ដែលជាអនុប្រធានបណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្ត បានទៅជួបរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដាក់ពាក្យបណ្តឹងដើម្បីអោយដោះស្រាយបញ្ហានៅក្នុងសហគមន៍ព្រៃឈើទាំង៥ក្នុងខេត្តឧត្តរមានជ័យ។

*១.២.៣-គាំទ្រចុះកិច្ចសន្យាជាមួយប្រជាជនដែលមានដីក្នុងព្រៃសហគមនិ ទប់ស្កាត់កុំអោយមានការកាប់រានបន្ត*

សហាគមន៍ភ្នំដងរែកសម្រែក ព្រៃស្រស់បានចុះធ្វើកិច្ចសន្ទនាដល់ប្រជាពលរដ្ឋដែលយកដីសហាគមន៍ប្រើប្រាស់ផ្ទាល់ខ្លួននៅក្នុងចំណុចត្រពាំងត្រាវបានចំនួន១៥គ្រួសារ ដោយសរុបផ្ទៃដីចំនួន៣០៣៦០០ម៉ែត្រការស្មើនិង៣០,៣៦ហាត ដើម្បីបញ្ឈប់ការកាប់បន្តទៀត ដោយមានកិច្ចសហការជាមួយ លោកអភិបាលស្រុករង មេឃុំ មេភូមិ និងគណៈកម្មការសហាគមន៍សរុបទាំងអស់មាន១៦នាក់ស្រី១នាក់។ លោកអភិបាលរងស្រុក និងមេឃុំគោកខ្ពស់ក្រោយធ្វើកិច្ចសន្ទនាជាមួយប្រជាជនទាំង១៥គ្រួសារហើយពួកគាត់បានបញ្ជាក់បន្ថែមថាព្រៃនេះនៅក្រោមការគ្រប់គ្រងសហាគមន៍ការពារអោយបានគង់វង្សសូមអោយបងប្អូនចូលរួមថែរក្សាការពារពីព្រោះព្រៃនេះគឺជារបស់យើងទាំងអស់គ្នា។ បើមានការបាត់ព្រៃឈើ និងមានបញ្ហាកើតឡើងទាក់ទងនិងការប្រែប្រួលអាកាសធាតុ វាអាចធ្វើអោយមានភាពរាំងស្ងួត ទឹកជនន់ និងខ្យល់ព្យុះជាដើម។ល។

*១.២.៥-វេទិការជួបជុំរីតចំណងសាមគ្គីរវាងអង្គការកែប្រែសហាគមន៍ និងក្រុមបណ្ដាញសហាគមន៍ក្នុងតំបន់គោលដៅ និងបូកសុរបសមទ្ធិផលជោគជ័យប្រចាំឆ្នាំ*

ការប្រជុំនេះមានការចូលរួមពី អភិបាលរងស្រុកពីរូប មេឃុំម្នាក់ ក្រុមប្រឹក្សាឃុំ២នាក់សរុបទាំងអស់២៣នាក់ និងស្រី៨នាក់។ ស៊ី ធី អូ បានបង្ហាញពីលទ្ធផលឆ្នាំ២០១៦កន្លងមក និងផែនការបន្ត។ អាជ្ញាធរទាំងប្រាំរូបបានធ្វើការគាំទ្រលើគម្រោងរបស់ស៊ីធីអូ និងសំនូមពរអោយម្ចាស់ជំនួយជួយរកបថវិកាបន្ថែមទៀតក្នុងការជួយគាំទ្រក្នុងការអភិវឌ្ឍន៍ដល់ភូមិ ឃុំ ស្រុក របស់ពួកគាត់បន្តទៅទៀត។

<u>**លទ្ធផលទី ១.៣៖**</u> ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដីសម្បទានសេដ្ឋកិច្ចចំនួន ២២១គ្រួសា(១០៩០ហិកតា) ដែលមិនទាន់មានការដោះស្រាយអាចស្វែងរកការគាំទ្រពីរដ្ឋាភិបាល និងដំណោះស្រាយសមស្របដោយសន្តិវិធី។

*១.៣.១-អញ្ជើញអ្នកមានបទពិសោធន៍រងផលប៉ះពាល់ដីធ្លីដែលទទួលបានការដោះស្រាយជោគជ័យមកចែករំលែកបទពិសោធន៍ដល់សហាគមន៍ដែលរងប៉ះពាល់*

តំណាងសហាគមន៍មកពីខេត្តព្រះវិហារចំនួនពីនាក់/ស្រីម្នាក់។ ពេជ ភ័ណ្ឌ តំណាងសហាគមន៍មកពីខេត្តព្រះវិហារ បានលើកឡើងពីបទពិសោធន៍ របស់លោក ចាប់ផ្ដើមឡើងតាំងពីឆ្នាំ១៩៩៧ ការទាមទារ ត្រូវមានទិន្នន័យច្បាស់លាស់ យល់ពីច្បាប់ និងមានការចូលរួមពីប្រជាជនទាំងអស់គ្នាទទួលខុសត្រូវទាំងអស់គ្នា។ លោកស្រី រឿង ខាន់ បានលើក ឡើងពីបទពិសោធន៍បន្ថែមក្នុងការស្វែងរកការគាំទ្រកន្លងមក គាត់ហ៊ានជជែកតទល់ជាមួយអាជ្ញាធរ មានអ្នកចូលរួមច្រើន កំលាំងចូលរួមការទាមទារសិទ្ធិជនជាតិដើមភាគតិច ជាក់ទងសិទ្ធិកាន់កាប់ដីព្រៃឈើ បច្ចុប្បន្ន នៅតែមិនបោះបង់គោលជំហរក្នុងការទាមទារកម្មសិទ្ធិស្របច្បាប់របស់គាត់ឡើយបើទោះនៅមានបញ្ហាជាច្រើនទៀតកំពុងប្រឈម។

*១.៣.២-ផ្សព្វផ្សាយ យុទ្ធសាស្ត្រស្វែងរកការគាំទ្រដោះស្រាយ និងអភិបាលកិច្ចក្នុងភូមិ*

ការផ្សព្វផ្សាយការគៀងគរស្វែងរកការគាំទ្របែបអហឹង្សាសកម្មនេះធ្វើឡើង៥ភូមិដែលមានបញ្ហាជាមួយប្រជាជនភូមិ កូនដំរី បាក់នឹម ស្រះកែវ ចារចាស់ ចារថ្មី ដែលមានការចូលរួមពីប្រជាជនចំនួន១៤៧នាក់/ស្រី៩០នាក់។ ក្នុងនោះពួកគាត់បានយល់ដឹងពី ខ្លឹមសារ និងអត្ថន័យនៃហឹង្សា ប្រភេទនៃហឹង្សាមាន អំពើហឹង្សាលើរូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងលើទ្រព្យសម្បត្តិ។ អត្ថន័យនៃអហឹង្សា និងអត្ថន័យនៃអហឹង្សាសកម្មគឺជាវិធីសាស្ត្រមួយដែល បុគ្គលអាចធ្វើការពាក់ព័ន្ធ នឹងស្ថានភាពទំនាស់ដោយមិនប្រើអំពើហឹង្សាពុំមែនអសកម្មភាព ការបំភ្លេចចោល ឬជៀសវាងទំនាស់នោះទេ។ គឺជាការតវ៉ា ការខំប្រឹងបញ្ចុះបញ្ចូលការពុំព្រមធ្វើសហប្រត្តិបតិការណ៍ (ករណីមានញឹកញាប់ជាងគេ) និងធ្វើអន្តរាគមន៍ដោយអហឹង្សា សំដៅធ្វើអោយឥទ្ធិពលភាគីជម្លោះដែលរំលោភច្បាប់ធ្វើអោយប៉ះពាល់ផលប្រយោជន៍នានាងាកមកគោរពច្បាប់។

**លទ្ធផលទី ១.៤៖**ប្រជាពលរដ្ឋដែលរងផលប៉ះពាល់៣៧៣គ្រួសារពីក្រុមហ៊ុន Synohydro នឹងមានសម្ថភាពយល់ដឹងពីសិទ្ធិនានារបស់ខ្លួនដែលមានចែងក្នុងច្បាប់ អាចធ្វើសកម្មភាពស្របច្បាប់ស្វែងរកការគាំទ្រពីរដ្ឋាភិបាលដើម្បី ទទួលបានដំណោះស្រាយដោយសន្តិវិធី។

*១.៤.១-ភ្ជាប់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ (អង្គការនានា អាជ្ញាធរ សហគមន៍ផ្សេងៗ)*

ការទំនាក់ទំនងនេះបានជួបជាមួយADHOCខេត្តឧត្តរមានជ័យដោយលោកបាន បញ្ជាក់ថាទំនប់ទឹកSinohydroនេះ នឹងត្រូវលិចលង់ផ្ទៃដីពី៣០០០ហិតានៅរដូវប្រាំងនិង ប្រហែល៦០០០ហិកតា នៅរដូវវស្សា ដែលនឹងលិចលង់ប៉ះពាល់ដល់ភូមិចំនួន៤ មានភូមិស្រះឃាយឈឿក ស្ថិតនៅឃុំពង្រ ស្រុកចុងកាល់ និងភូមិសំព័រ ទំនប់ថ្មី ចារ្យថ្មី ឃុំលំទង ស្រុកអន្លង់វែង និង បាក់នឹម សង្កាត់សំរោង ក្រុងសំរោង។ ភូមិចារ្យចាស់ នៅឃុំស្លែងស្ពាន ស្រុកស្រីស្នំ ខេត្តសៀមរាប។ ទំនប់ទឹកនេះ ឆ្លងកាត់ស្រុកចុងកាល់ ស្រីស្នំ រហូតដល់ស្រុកភ្នំស្រុកខេត្តបន្ទាយមានជ័យ។ ប្រជាជន ងើបឡើង តវ៉ាមិនអោយសាងសង់ដោយសារពុំទាន់មានសំនងដីដែលប៉ះពាល់ ទើបមានដីការពីតុលាការចាប់ខ្លួន តំណាងអ្នកភូមិស្រះកែវចំនួន៣នាក់ ចំនួនរយៈពេល ៣ខែ តែឥឡូវនេះកំពុងត្រូវបានដោះ លែង នៅក្រៅឃុំស្ថិត ក្នុងការស៊ើបអង្កេតរបស់តុលាកា។ ក្នុងថ្ងៃនេះដដែលបានជួបជាមួយព្រះតេជគុណប៊ុនសាលួតលោកបានបញ្ជាក់ក្រុមហ៊ុននេះមិនមានការ បង្ហាញច្បាប់អ្វីទេ រហូតដល់ពេលនេះក្រុមហ៊ុនមិនបានអោយច្បាប់ប្រជាជនណាម្នាក់បានឃើញឡើយ នៅពេលក្រុមហ៊ុនបិទទំនប់រួចប៉ះពាល់ដល់ដីព្រៃសហគមន៍របស់ព្រះតេជគុណចំនួន៣០០០ហិកតា លិចប្រាសាទបូរាណចំនួយ៦កន្លែង ប្រជាជននៅភូមិស្រះឃាយឈឿកនឹងត្រូវផ្លាស់ប្តូរភូមិទៅកន្លែងផ្សេងទៀត។ ក្រុមហ៊ុនចូលមកតាំងពីខែមិថុនាឆ្នាំ២០១៥។ លោកបានអោយឈ្មោះអ្នកពាក់ព័ន្ធដែលត្រូវទំនាក់ទំនងសាកសួរពីពត៌មានប្រជាជនដែលរងផលប៉ះពាល់ដោយសារការបិទទំនប់នេះ។ បន្ទាប់មកបានជួបជាមួយប្រជាជននៅភូមិបាក់នឹម ពួកគាត់៧នាក់/ស្រី៤នាក់ ពួកគាត់ដឹងថានៅពេលបិទទំនប់នឹងមានការប៉ះពាល់ ប៉ុន្តែពួកគាត់កំពុងតែនៅចាំរាជរដ្ឋាភិបាលដោះស្រាយអោយ។ ផ្ទះរបស់គាត់នឹងលិចដល់ទៅ២ម៉ែត្រនៅរដូវវស្សា។ ពួកគាត់មានសំនូមពរអោយក្រុមហ៊ុនជួយដោះស្រាយដល់ពួកគាត់។ ជាបន្តបានជួបជាមួយប្រជាជននៅភូមិស្រះកែវចំនួន២៣នាក់/ស្រី១៧នាក់ ពួកគាត់កំពុងតែមានការអស់សង្ឃឹម ដោយពុំទាន់មានការដោះដូរដីដែលប៉ះពាល់អ្វីសោះ ក្រុមហ៊ុនមានសកម្មភាពសាងសង់រាល់ថ្ងៃ។ ភូមិនេះនៅពេលបិទទំនប់រួចត្រូវតែផ្លូវលំនៅដ្ឋានទៅនៅកន្លែងផ្សេងទាំងស្រុង។ ពួកគាត់មានការសោកស្តាយនៅពេលបានបង់ព្រៃសហគមន៍ជាច្រើនពាន់ហិកតា។ ដែលពួកគាត់រកចំណូលពីផលអនុផលព្រៃឈើជាប្រចាំទៅតាមរដូវកាលក្រៅពីរដូវប្រមូលផលស្រែចំការ។ ភូមិនេះនឹងប៉ះពាល់ដល់ប្រជាជនចំនួន១៥៤គ្រួសារនិងប៉ះពាល់ដីស្រែពី៨០០ ទៅ១,០០០ហិកតា។ កាលពីមុនពួកគាត់មានការតវ៉ាយ៉ាងខ្លាំង តែដោយមានការចាប់អ្នកតំណាងដាក់គុកចំនួន៣នាក់ ពួកគាត់មានការខ្លាចមិនហ៊ានទាមទាទៀតឡើយ។ ពួកគាត់កំពុងតែរងចាំការដោះស្រាយនេះពីរាជរដ្ឋាភិបាល។ ជាបន្តការជួបជាមួយអនុភូមិចារ្យថ្មី ប្រជាជនមាន១៦១គ្រួសារ ប្រជាជនសរុប៨៣២នាក់/ស្រី៤១២នាក់ដែលប៉ះពាល់ដីស្រែចំនួន៣០០ហិកតាជាង។ តាមការសម្ភាសន៍មេភូមិចារ្យថ្មី គាត់ទទួលខុសត្រូវ៣ភូមិ ចារ្យចាស់ ចារ្យថ្មី និងកត្លួ/ស្រុកចុងកាល់ប៉ះពាល់ចំនួន៥,០០០ហិកតា។ ជាបន្តបានជួបជាមួយមេភូមិចារ្យចាស់ មានប្រជាជនសរុប១៦១គ្រួសារ និងមនុស្សសរុប៦៥០/ស្រី៣៥០នាក់។ មានប្រជាជនដែលប៉ះពាល់ចំនួន១៦គ្រួសារ ដីស្រែចំនួន១០០ ហិកតា និងដីចំការ៦០ហិកតា។ ជាចុងក្រោយបានជួបអ្នកភូមិគោកសំព័រចំនួន៧នាក់/ស្រី៣នាក់។ ភូមិនេះមានការប៉ះពាល់ដល់ប្រជាជនចំនួន៩០គ្រួសារ និងប៉ះពាល់ដល់ដីស្រែចំការ លំនៅដ្ឋាន ចំនួន៥៦៦ហិកតា។ ពួកគាត់ធ្លាប់មានការទាមទារចំនួន៣ដង នៅឆ្នាំ២០១៥ តែពុំមានលទ្ធផលអ្វីទេ។

*១.៤.២-សិក្សាពីទិន្នន័យគោល របស់ទំនប់ទឹកស្រុកចុងកាល់ អន្លង់វែង សំរោង*

ប្រជាជនមកពី៤ភូមិគឺនៅភូមិ ស្រះកែវ ទំនប់ថ្មី គោកសំព័រ បាក់នឹមបានទៅធ្វើការទាមទារដីសំណងពីក្រុមហ៊ុនSinohydro ចំនួន៣លើកដែលមានការចូលរួមពីប្រជាជនចំនួន៤២២នាក់/ស្រី២៤២នាក់។ ក្រោយពីតវ៉ាអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត

និងគណៈកម្មការអន្តរក្រសួងបានចុះមកដោះស្រាយ មានការត្រួតពិនិត្យដីជាក់ស្តែងតាមគ្រួសារនីមួយៗ និងអោយប្រជាជននៅស្រះកែវអាចបង្កបង្កើនផលលើដីចាស់របស់ពួកគាត់ និងបានចែកដីលំនៅឋានដល់ប្រជាជននៅស្រះកែវចំនួន១២៣គ្រួសារ ដែលមានទំហំ ៥០០mX១០០m ក្នុងមួយគ្រួសារ។ នៅសល់៣៥គ្រួសារទៀតដែលមិនទាន់ទទួលបានសំណង។ ប្រជាជនមានផែនការទាមទារសំណងនៅខែកក្កដាបន្តទៀត។ មានការចូលរួមពីសមាជិកចំនួន៩នាក់ មកពីភូមិស្រះកែវ ទំនប់ថ្មី គោកសំព័រ ក្នុងនោះស្ត្រីសរុបចំនួន២នាក់ ពួកគាត់បានពិភាក្សារពីបាយការណ៍ កន្លងមកទាក់ទងសំណងរបស់ក្រុមហ៊ុនSinohydro។ តំណាងសហគមន៍ទាំងបីភូមិបានរាយការណ៍ពីការតវ៉ាដើម្បីទាមទារសំណងកន្លងមក។ បន្ទាប់មកទៀតបានបង្ហាញពីអត្ថន័យនៃការស្វែងរកការគាំទ្រគឺជា ដំណើរការរៀបចំសកម្មភាពរបស់បុគ្គលឬក្រុមមនុស្ស ដែលមានតម្រូវការដូចគ្នាដើម្បីបញ្ចុះបញ្ចូល និងធ្វើអោយមានឥទ្ធិពលដល់បុគ្គលទាំងឡាយដែលមានតួនាទីសំខាន់ក្នុងជួររដ្ឋាភិបាលអ្នកនយោបាយឬអ្នកមានឥទ្ធិពលខាងសេដ្ឋកិច្ច ដើម្បីអោយពួកគេគោរពទៅតាមគោលនយោបាយសាធារណៈក្នុងគោលបំនងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលគ្មានអំណាច ផ្នែកនយោបាយ ឬអ្នកដែលគ្មានធនធានសេដ្ឋកិច្ចតិចតួច។ វិធីសាស្ត្រក្នុងការស្វែងរកការគាំទ្រនេះមាន ដូចជា:បញ្ចុះបញ្ចូល ការចរចារ ការប្រឈមមុខដោយសន្តិវិធី។

- ការបង្កើតសំនួរ និងមានការពិភាក្សាជាមួយតំណាងសហគមន៍
  ក្នុងការពិគ្រោះយោបល់នេះ១៦នាក់ស្រីចំនួន៨នាក់បញ្ជីសំនួរត្រូវបានបង្កើតឡើងចំនួនពីគឺ បញ្ជីសំនួរសម្រាប់សួរដល់សហគមន៍ និងបញ្ជីសំនួរសម្រាប់សួរដល់អាជ្ញាធរពាក់ព័ន្ធ។
- ចុះទៅសំភាសន៍ និងពិភាក្សាក្រុមជាមួយប្រជាជនរងគ្រោះ
  អ្នកចូលរួម ត្រូវបានធ្វើការជ្រើសរើសដោយមានគោលដៅច្បាស់លាស់នៅក្នុងការស្រាវជ្រាវនេះ។ នៅតាមភូមិមានការជ្រើសរើសប្រជាជននឹងមានការប៉ះពាល់ជាមួយ Sinohydro ចំនួន៦ភូមិ ទៅតាមភូមិ ដែលរងផលប៉ះពាល់តិចឬច្រើន ដែលក្នុងនោះមានភូមិស្រះកែវ ១២នាក់ ក្នុងនោះ អនុភូមិ ម្នាក់ ភូមិចារចាស់៨នាក់/មេភូមិម្នាក់ ភូមិទំនប់ថ្មី ៧នាក់/អនុភូមិម្នាក់ ភូមិចារថ្មី៥នាក់/អនុភូមិម្នាក់ ភូមិ គោកសំព័រ១៧នាក់/មេភូមិម្នាក់ ភូមិបាក់នឹម៩នាក់/មេភូមិម្នាក់ និងព្រះតេជគុណ ប៊ុន សាលួត មួយអង្គ និងមានសម្ភាសន៍អាជ្ញាធរពាក់ព័ន្ធមិនផ្លូវការតាមទូរស័ព្ទ និងជួបដោយផ្ទាល់។ សរុបមេភូមិ និងអនុភូមិ ចំនួន៦នាក់ លោកសង្ឃមួយអង្គ និងប្រជាជន ចំនួន ៥៣នាក់/ស្ត្រីចំនួន ។
- ប្រជុំឆ្លុះបញ្ចាំងដើម្បីកែតម្រូវរបាយការណ៍
  ធ្វើការបង្ហាញពីរបាយការណ៍ និងធ្វើការអាន និងកែតម្រូវទាំងអស់គ្នា ដែល ក្នុងរបាយការណ៍មានដូចជា: បុព្វកថា ប្រវត្តនៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការធ្វើការស្រាវជ្រាវ វិធីសាស្ត្រនៃការធ្វើការស្រាវជ្រាវការរកឃើញសំខាន់ៗ ស្វែងយល់ពីបច្ចុប្បន្នភាពរបស់ប្រជាជនដែលស្ថិតនៅជុំវិញទំនប់ទឹក Sinohydro សិក្សាពីផលប៉ះពាល់របស់ប្រជាជននៅពេលសាងសង់ទំនប់រួច ស្វែងយល់ពីសកម្មភាពរបស់សហគមន៍កន្លងមក តម្រូវការបន្ត និងយុទ្ធសាស្ត្រថ្មីៗរបស់សហគមន៍ក្នុងការទាមទារសំណង។ សហគមន៍បានយល់ដឹពីឯកសារទាក់ទងនឹងគោលការណ៍សំណងរបស់រដ្ឋាភិបាល និងនីតិវិធីការអនុវត្តការដោះស្រាយផលប៉ះពាល់លើគម្រោងអភិវឌ្ឍន៍នានា គម្រោងសាងសង់ទំនប់ទឹករបស់ក្រុមហ៊ុន Sinohydro ជំហ៊ានទី២សម្រាប់ខេត្តឧត្តរមានជ័យ។

*១.៤.៣-ប្រឹក្សាយោបល់ជាមួយមេធាវី ADHOC Media Radio រឿងដីធ្លី ធ្វើការទាក់ទងជាមួយប្រពន្ធ័ផ្សព្វផ្សាយឯករាជ្យដើម្បីផ្សព្វផ្សាយពីបញ្ហាបទល្មើសព្រៃឈើ នៅក្នុងសហគមន៍ព្រៃឈើ ខេត្តឧត្តរមានជ័យ។*

តំណាងអ្នករងផលប៉ះពាល់ដីធ្លីចំនួន៦នាក់ស្រី១នាក់បានរៀបចំកិច្ចប្រជុំដើម្បីពិភាក្សាអំពីការឡើងមកជួបអាជ្ញាធរ សង្កាត់ ក្រុង ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាដីធ្លីនៅក្នុងភូមិ ចំនួន៥ ភូមិ គឺមានភូមិ បុស្ស ភូមិបាក់និម ភូមិអូរបាត់មាន់

ភូមិតាម៉ាន និងភូមិស្រះព្រិច ចាប់ពីថ្ងៃទី០៨ដល់ថ្ងៃទី១៩ខែមករាឆ្នាំ២០១៦។ បានចុះពិនិត្យស្នាមមេដៃជាមួយគ្រួសាររងគ្រោះបានចំនួន២១៩គ្រួសារ ហើយពួកគាត់បានយកពាក្យបណ្តឹងមកដាក់ជូនស្ថាប័នពាក់ព័ន្ធ ដូចជា អង្គការADHOC អង្គភាពប្រឆាំងអំពើពុករលួយ អង្គការCTO សង្កាត់កូនគ្រៀល និងសាលាក្រុងសំរោង។ សាលាក្រុងសំរោងនឹងដាក់លិខិតនេះបញ្ជូនទៅឯកឧត្តមអភិបាលខេត្តត្រួតពិនិត្យ។ សាលាក្រុងសំរោងបានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុងប្រចាំឆ្នាំ២០១៦។ មានតំណាងសហគមន៍រងគ្រោះដីធ្លីចំនួន៧នាក់ ស្រី២នាក់ បានចូលរួម។ មានការពិភាក្សាពីបញ្ហាព្រៃសហគមនិរតនរុក្ខា ដែលមានការកាប់បំផ្លាញយ៉ាងខ្លាំងពីជនល្មើស និងបានលើកឡើងពីការឆក់ត្រី ដែលមានលក្ខណៈជាប្រពន្ធ័នៅក្នុងតំបន់ហាមឃាត់ លោកស្រី ហូយ ម៉ៃ បានលើកបញ្ហាដីធ្លីនៅត្រង់ចំនុចភូមិអូរបាត់មាន់ ដែលមានទាន់មានដំណោះស្រាយ មកពិភាក្សា លោកម៉ា អ៊ុកជឿន ស្នើសុំអន្តរាគមន៍ដើម្បីទទួលបានដំណោះស្រាយដីធ្លី និងអោយគាត់គេចផុតពីការចោទប្រកាន់របស់តុលាការមកលើរូបគាត់

ផែនការបន្តរបស់សហគមន៍:

- តំណាងសហគមន៍ នឹងមកជួបនៅសាលាខេត្តសារជាថ្មី បើពុំមានដំណោះស្រាយ
- ស្វែងរកការគាំទ្រពីអង្គការនានាដើម្បីជួយដល់ពួកគាត់
- ស្វែងរកការគាំទ្រដើម្បីយកញត្តិទៅដាក់នៅតាមក្រសួងពាក់ពន្ធ័ដើម្បីរកដំណោះស្រាយ

*១.៤.៣-ភ្ជាប់បណ្តាញជាមួយបណ្តាញNGO Forum ទាក់ទងទៅនិងបញ្ហាដីធ្លីព្រៃឈើ*

អង្គការស៊ីធីអូ បានធ្វើការចូលរួចរាល់ជាសមាជិកបណ្តាញព្រៃឈើនិងREDD+ និងជាមួយ NGOs forum សម្រាប់ឆ្នាំ២០១៦

**លទ្ធផលទី ២.១៖**កុមារចំនួន ២,៨៤១នាក់/កុមារី១,៣១៨នាក់ នៃឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ទទួលបានការសិក្សាបរិយាកាសនៃការសិក្សា ប្រសើរជាងមុន តាមរយៈ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។

*២.១.១-ប្រមូលសារកុមារ*

ឆ្នាំ ២០១៦ ស៊ីធីអូ បានធ្វើការប្រមូលសារ សម្រេចបាន១០០% បើធៀបនិង សុច្ចនករ ដែលមានចែងនៅក្នុងផែនការប្រចាំឆ្នាំ២០១៦សរុបទាំងអស់១៨ភូមិ។ បុគ្គលិករបស់អង្គការ ស៊ី ធី អូ បានចុះអនុវត្តន៍ទៅតាមភូមិ គោលដៅដោយមានការសហការជាមួយមេភូមិ និងអ្នកគ្រូស្ម័គ្រចិត្ត នៅតាមភូមិនិមួយៗដើម្បីធ្វើការប្រមូលសារប្រចាំត្រីមាសទី៤ ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួនអ្នកចូលរួមសរុបៈ ៥៨១នាក់ ស្រីៈ៣៣៨នាក់។ ការយល់ដឹងរបស់កុមារៈ គឺអោយកុមារដឹងពីផលប្រយោជន៍នៃការគូររូបរបស់គេ អោយចេះសំអាតខ្លួនប្រាណចេះដុសធ្មេញ និងចេះលាងដៃមុនពេលហូបចំនីអាហារ។ លទ្ធផលដែល ទទួលបានកុមារចេះជួយពន្យល់មិត្តភក្តិមកចូលរួមគូររូប កុមារដែលគូររូបបានស្អាត ជួយបង្រៀនកុមារដែលពុំសូវចេះគូររូបអោយចេះគូរ និងចេះសំអាតខ្លួនមុនពេលទៅសាលា ចេះលាងដៃមុនពេលហូបចំនីអាហារ ។

*២.១.២-កម្មវិធីប្រចាំឆមាស ប្រលងប្រជែងស្នាដៃល្អ និងល្បែងប្រជាប្រិយ៍សម្រាប់កុមារ*

ស៊ី ធី អូ បានរៀបចំការប្រកួតប្រជែងប្រលងគំនូរកុមារនៅមន្ទីរផែនការខេត្ត ដែលមានអ្នកចូលរួមសរុប ៥៣នាក់ស្រី៣៥នាក់ ដែលមាន កុមារចូលរួមពី ១៨ភូមិ គឺភូមិដូនកែន ឈូក ពុរ អូរកន្សែង អូរឬស្សី ឆ្អើប បន្សាយរាក់ អូរទេង សំបូរមាសត្នោត ពោធិវង្ស ឈើស្លាប់ គាប គោកខ្ពស់ ព្រៃទទឹង ប្រិយ៍ គោកច្រេស រំដួលវាសនា។ កុមារបានទាំងអស់បានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការគូរគំនូរ និងផលប៉ះពាល់នៃការបាត់បង់ព្រៃឈើ។ ជាពិសេសកុមារបានបញ្ចេញស្នាដៃរបស់ខ្លួន និងលើកទឹកចិត្តអោយកុមារចង់ចូលរួមក្នុងការគូរសារ ក្នុងកម្មវិធីនេះ មានការលើកទឹកចិត្តកុមារទាំងអស់ដែលបានលេខ ១ ដល់លេខ ៣ ទទួលបានកង់១ ការបូប១ សៀវភៅ ៣ក្បាល ប៊ិច ១គូ ចំពោះអ្នកលេខ ៤ ចុះក្រោម ទទួលបាន ការបូប១

សៀវភៅ២ក្បាល ប៊ិច១គូ។ សម្ភារៈសិក្សាទាំងអស់នេះដើម្បីជំរុញអោយកុមារ តាំងចិត្តក្នុងការសិក្សា ជាពិសេសកុមារដែលបោះបង់ការសិក្សាអោយពួកគាត់ចងចូលចូលរៀនវិញ ក្រោយពីទទួលបានសម្ភារៈសិក្សា ទាំងនេះ។

*២.១.៣-ប្រជុំគ្រូស្មគ្រ័ចិត្តចំនួន២៦នាក់រៀងរាល់៣ខែម្តង*

នៅការិយាល័យអង្គការCTOនៅខេត្តឧត្តរមានជ័យបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយអ្នកសំរបសំរួលសហគមន៍ដងក្នុងមួយឆ្នាំ។អ្នកចូលរួមទាំងអស់ ២៩នាក់ ស្រី ២៧នាក់ ប្រុស ២នាក់។ គ្រូស្ម័គ្រចិត្តទាំងអស់បានយល់ដឹងច្បាស់ពីកម្មវិធីកុមារនិងការគ្រប់គ្រងកុមារនៅក្នុងសហគមន៍។ ហើយពួកគាត់បានយល់ដឹងពីតួនាទីរបស់ខ្លួនដូចជាៈ

- គ្រូបង្គោលត្រូវមានភាពទទួលខុសត្រូវទាំងសម្ភារៈ
- តារាងឈ្មោះសិស្សគូរសានិងទីកន្លែងដាក់លាក់
- ធ្វើការទំនាក់ទំនងជាមួយឪពុកម្តាយ អជ្ញាធរ និងលោកគ្រូអ្នកគ្រូ
- ផ្តល់ពត៌មានដល់ក្មេងនៅពេលមានការចុះជួបពីអង្គការ ស៊ី ធី អូ
- អប់រំ និងពន្យល់ ដល់ក្មេងអំពី ប្រយោជន៍នៃការគូរសា
- ផ្តល់ពត៌មានមកអង្គការ នៅពេលមានករណីចាំបាច់ដូចជា (រំលោភ ជួញដូរ ឬហឹង្សាកុមារជាដើម)
- រៀបចំផែនការសកម្មភាព មុនពេលចុះនាំក្មេងគូរសា
- ពន្យល់ ពីរបៀប ផាត់ពណ៌ របៀបគូរសា ត្រួតពិនិត្យសារ និងសម្របសម្រួលក្នុងការគូរស
- ជាពិសេសអ្នកគ្រូស្ម័គ្រចិត្តទាំង២០ ភូមិបានយល់ដឹងពីៈ
    - កម្មវិធីកុមារកាន់តែច្បាស់ ជួយបញ្រ្ជាប់ដល់កុមារ និងឪពុកម្តាយក្មេងគូរសារអោយបានយល់ពីកម្មវិធីគូរសារ
    - ឧបករណ៍ តាមដានកុមារចំណាកស្រុក
    - ឧបករណ៍វាស់វែងពីគ្រួសារកុមារ និង កុមារផ្ទាល់ដែលទទួលផលពីគម្រោង
    - គ្រូស្ម័គ្រចិត្តបានធ្វើផែនការរួមគ្នាសម្រាប់ប្រមូលសារកុមារលើកទី១ ឆ្នាំ២០១៦ ដើម្បីពួកគាត់ងាយស្រួលក្នុងការសហការក្នុងការអនុវត្តការងារ។

*២.១.៤-កម្មវិធី បំណិនជីវិត*

ស៊ីធីអូបានសហការណ៍ជាមួយនាយកសាលា រៀបចំធ្វើបំនិនជីវិតនៅតាមសាលារៀនចំនួន៦សាលា គឺសាលាបឋមសិក្សាពោធិវង្សត្នោត បន្សាយរាក់ ឆ្អើប សំបួរមាស និងវំដួលវាសនា ដែលមានអ្នកចូលរួមសរុប១៥៨ នាក់ ស្រី៧៧នាក់។ កុមារដែលលចូលរួមបានយល់ដឹងពីរការដាំបន្លែ វិធីសាស្រ្តនៃការលាយជី និងរបៀបនៃការថែទាំបន្លែ។ ជាពិសេសពីរបៀបនៃការកែច្នៃរបស់សំណល់មកធ្វើឲ្យមានប្រយោជន៍ដូចជា យកសំបកកង់ឡាន ឬកង់ម៉ូតូ ការ៉ុង និងសំបកដប មកដាំបន្លែដោយមិនបាច់ចំណាយដី សម្រាប់ដាំច្រើន ឬទឹកច្រើនសម្រាប់ស្រោច ហើយពួកគាត់អាចយកគំនិតនេះទៅកែច្នៃដាំបន្លែនៅផ្ទះដោយខ្លួនឯងបាន ពួកគាត់អាចយកគំនិតទាំងនេះទៅបង្ហាញដល់ឪពុកម្តាយ បងប្អូន និងមិត្តភក្តិរបស់គាត់ផ្សេងទៀតដើម្បីចេះដាំបន្លែនេះដែរ។

*២.១.៥-ចូលរួមទិវាសិទ្ធិកុមារ អន្តរជាតិ១មិថុនា និងវេទិកាសាធារណៈថ្នាក់ឃុំទាំង៣*

អង្គការស៊ីធីអូបានរៀបចំកម្មវិធី ទិវាកុមារអន្តរជាតិ១មិថុនា ចំនួន២សង្កាត់ គឺសង្កាត់សំរោង សង្កាត់បន្សាយរាក់ និង១ឃុំ។ ទិវានេះធ្វើឡើងបីឃុំសង្កាត់ មានសំរោង បន្សាយរាក់ គោកខ្ពស់ ដោយមានអ្នកចូលរួមសរុបចំនួន ១.៧២១នាក់ស្រី ១.០១១នាក់។ អ្នកចូលរួមទាំងអស់ ជាពិសេសកុមារបានដឹងពីប្រវត្តិទិវាកុមារអន្តរជាតិ ១មិថុនា ដ៏មានអត្ថន័យ បង្កប់នូវភាពឈឺចាប់របស់កុមារពីអតីត ដាស់អារម្មណ៍សិស្សានុសិស្សឲ្យមានភាពក្លាហាន ហានបញ្ចេញនូវអ្វីដែលខ្លួនមាន អោយអស់

ពីសម្តភាព ហើយមាតាបិតាសិស្សបានយល់ច្បាស់ពីការចូលរួមការពារ និងថែទាំកុមារ ពួកគាត់មានឪកាសក្នុងការសួរការិយាល័យអប់រំ នាយកសាលា ពីការរៀន និងការបង្រៀន និងការអភិវឌ្ឍន៍សាលារៀនកន្លងមក។ក្នុងនោះដែរសិស្សានុសិស្សបាន ស្ម័គ្រចិត្តឡើងបេះផ្កាប្រជាធិបតេយ្យ ដើម្បីឆ្លើយសំនួរ យករង្វាន់ដូចជា សៀវភៅ ប៊ិច ច្រៀងចម្រៀង បង្ហាញម៉ូត ដើម្បីឲ្យកម្មវិធីមានភាពសប្បាយបន្ថែមទៀត។

<u>**លទ្ធផលទី ២.២**</u>**៖** គណៈកម្មការទ្រទ្រង់សាលាទាំង២០សាលា បានអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងសាលារៀនប្រសើរជាងមុន ហើយប្រជាជន រួមទាំងកុមារចំនួន៧០០នាក់/ស្ត្រី៤០០នាក់ បានយល់ដឹងពីពីការលើកកំពស់សិទ្ធិក្នុងសាលារៀន(PRS)

*២.២.១-ផ្សព្វផ្សាយPRSទៅដល់ក្លិបកុមារទាំង១០ភូមិ*

ស៊ីធីអូ បានរៀបចំការផ្សព្វផ្សាយពីគោលការណ៍សិទ្ធិទាំង១០នៅក្នុងសសាលារៀន នៅមន្ទីរផែនការខេត្តឧត្តរមានជ័យ។ មានអ្នកចូលរួមសរុប ៥៣នាក់ ស្រី៣៥នាក់ ដែលមានកុមារចូលរួមពី ១៨ភូមិ គឺភូមិដូនកែន ឈូក ពុរ អូរកន្សែង អូរឬស្សី ឆ្អើប បន្សាយរាក់ អូរទង សំបូរមាស ត្នោត ពោធិវង្ស ឈើស្លាប់ គាប គោកខ្ពស់ ព្រៃទទឹង ប្រិយ៍ គោកច្រេស រំដួលវាសនា។ កុមារដែលលបានចូលរួមបានយល់ដឹងច្បាស់ពីសិទ្ធិទាំង១០នៅក្នុងសាលារៀនចាប់ពីសិទ្ធិទី១ ដល់ សិទ្ធិទី១០ ការផ្សព្វផ្សាយនេះធ្វើអោយកុមារ និងលោកគ្រូអ្នកគ្រូបានយល់ដឹងច្បាស់ពីសិទ្ធិកុមារនៅក្នុងសាលារៀន ធ្វើអោយកុមារមានភាពក្លាហានក្នុងការសិក្សា ហ៊ានសម្រេចចិត្ត ធ្វើអោយលោកគ្រូ អ្នកគ្រូកាន់តែយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្សប្រកបដោយគុណភាព និងមិនរំលោភសិទ្ធិរបស់កុមារ ជាពិសេសលោកគ្រូ អ្នកគ្រូ ជួយជំរុញឲ្យមាតាបិតាសិស្សជួយជំរុញកូនឲ្យទៅសាលារៀន ។

<u>**លទ្ធផលទី ៣.១**</u>**៖**ស្ត្រីជាមេដឹកនាំសហគមន៍ចំនួន៧៦នាក់ និងក្រុមប្រឹក្សាឃុំ ដែលទទួលបន្ទុក(គកនក)៦នាក់ក្នុងឃុំសំរោង បន្សាយរាក់ និងគោកខ្ពស់ បានប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍ភូមិឃុំរបស់ពួកគាត់។

*៣.១.១-ផ្សព្វផ្សាយ និងវិភាគយេនឌ័រ អំពើហឹង្សាក្នុងគ្រួសារ ពីការងារបុរសស្ត្រី តាមភូមិគោលដៅដើម្បីឆ្លុះបញ្ចាំងពីការសកម្មភាពតាមភូមិ ទាក់ទង យេនឌ័រ សិទ្ធិស្ត្រី និងអំពើហឹង្សាក្នុងគ្រួសារ*

CTO បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយដល់ប្រជាជន និងសមាជិកក្រុមស្តី ពីការវិភាគការងាររវាងបុរស ស្ត្រី ក្នុងសហគមន៍ សិទ្ធិក្នុងការសំរេចចិត្ត និងផលប៉ះពាល់ការប្រើអំពើហឹង្សាក្នុងគ្រួសារ ក្នុងភូមិ៧ មានភូមិខ្ញុំ ភូមិតាម៉ាន ភូមិត្នោត ភូមិឆ្អើប ភូមិឈូក ភូមិសំបូរមាស និងភូមិដូនកែន ដោយមានអ្នកចូលរួមចំនួន៣០៩នាក់ ស្រី២១០នាក់។

- អ្នកចូលរួមចំនួន៣០៩នាក់ ១៥០នាក់បានយល់ដឹងអំពីការងាររវាងបុរសស្រីច្បាស់និងអាចយកទៅធ្វើការផ្សព្វផ្សាយបន្តដល់អ្នកជិតខាងបាន។
- អ្នកចូលរួមចំនួន៣០៩នាក់២០០នាក់បានយល់ដឹងអំពីសិទ្ធិការធ្វើសេក្តីសំរេចចិត្តក្នុងក្រុម និងក្រុមគ្រួសារ។
- អ្នកចូលរួមចំនួន៣០៩នាក់បានយល់ដឹងពីផលប៉ះពាល់នៃប្រើអំពើហឹង្សានៅក្នុងគ្រួសារនិងធ្វើអោយ មានការបាត់បង់នៅប្រាក់ចំណូល ខាតពេលវេលា ជាពិសេសអាចប៉ះពាល់ដល់អារម្មណ៍របស់កូនកំពុងរៀនសូត្រជាដើម។ល។

<u>**លទ្ធផលទី ៣.២**</u>**៖** សមាជិកសហគមន៍ចំនួន៥០០នាក់/ស្ត្រី៣០០នាក់ បានយល់ដឹងពីតួនាទីយេនឌ័រ និងតួនាទីភេទ

*៣.២.១-បង្កើតគោលការយេនឌ័រ នៅក្រុមទាំង ២១ក្រុម មានក្រុមសន្សំ និងធនាគារស្រូវ*

បានធ្វើការរៀបចំប្រជុំជាមួយសមាជិកគណៈកម្មការ និងអាជ្ញាធរភូមិដើម្បីធ្វើការពិភាក្សារៀបចំបង្កើត អោយមានគោលការណ៍យេនឌ័រនៅក្នុងធនាគារស្រូវ និងក្រុមសន្សំប្រាក់ចំនួន២០ភូមិ ទទួលស្គាល់ពីមេឃុំរួចហើយ។ អ្នកចូលរួមចំនួន៥២៣

នាក់ក្នុងនោះមានស្រ្តីចំនួន៤២៤នាក់  អ្នកចូលរួមទាំងបុរសស្រ្តីបានធ្វើការឯកភាពគ្នាក្នុងការបង្កើតអោយមានគោលការណ៍យេនឌ័រនេះឡើង។ ពួកគាត់បានធ្វើការបញ្ជាក់ថាពេលមានគោលការណ៍នេះហើយវាអាចអោយ ក្នុងក្រុមសន្សំធនាគារស្រូវទាំងបុរសស្រ្តីធ្វើការសំរេចចិត្តដោយមានសមភាព និងសមធម៌នៅក្នុងសង្គមឬនៅក្នុងក្រុមគ្រួសារ គ្មានអំពើហឹង្សាកើតឡើងជាពិសេសពេលមានគោលការណ៍នេះ និងធ្វើអោយបុរសស្រ្តីមានសិទ្ធិក្នុងការចូលរួមបញ្ចេញមតិយោបល់បានស្មើគ្នា។

*៣.២.២-ស្រ្តីជាសមាជិកសហគមន៍ចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ*

ការធ្វើកាផែនការវិនិយោគឃុំ  និងអភិវឌ្ឍន៍ឃុំស្រ្តីពុំសូវមានការចូលរួមសម្រេចចិត្តច្រើនទេ  ក្នុងការលើកឡើងពីតម្រូវការរបស់ខ្លួន  ការជំរុញអោយស្រ្តីក្នុងការលើកឡើងពីតម្រូវការ  និងមានសម្លេងក្នុងការបញ្ចេញមតិយោបល់ជាចាំបាច់  ដើម្បីអោយមានបទអន្តរាគមន៍របស់ឃុំសង្កាត់ឆ្លើយតាមនឹងតម្រូវការជាក់ស្តែងរបស់ពួកគាត់សកម្មភាពនេះធ្វើឡើងចំនួន២០ភូមិ

## IV. របាយការណ៍ហិរញ្ញវត្ថុ

<u>គម្រោងទី១</u>

| បរិយាយ | ចំនូលសរុប ២០១៦ | ផែនការថវិកា២០១៦ | ចំណាយ២០១៦ | សមតុល្យ |
|---|---|---|---|---|
| បុគ្គលិក | Total in come 2016 =61146.16$ | 22320 $ | 22320 $ | |
| រដ្ឋបាល | Balance forward from 2015=2547.18$ | 4680.00$ | 4652.60$ | |
| កម្មវិធី | | 43505.00$ | 35566.14$ | |
| **សរុបរួម** | **63693.34$** | **70505.00$** | **62538.74$** | **1154.60$** |

<u>គម្រោងទី២</u>

| បរិយាយ | ចំនូលសរុប ២០១៦ | ផែនការថវិកា២០១៦ | ចំណាយ២០១៦ | សមតុល្យ |
|---|---|---|---|---|
| រដ្ឋបាល<br>បុគ្គលិក | 59,585.36$ | 36,572$ | 36,429.97$ | |
| កម្មវិធី | | 22,809$ | 22,791.17$ | |
| **សរុបរួម** | **59585.36$** | **59,381$** | **59,221.14$** | **364.22$** |

## V. ឧបសគ្គរាំងស្ទះនិងមេរៀន

គម្រោងទី១៖

**ក-ឧបសគ្គរាំង**

- ភ្លៀងធ្លាក់មិនទៀងទាត់ខុសប្រក្រតី បង្កើតជាស្ថានភាព បើមានទឹកមានជ្រុល បើខ្វះៗជ្រុល ជាពិសេសទឹកជំនន់កើតឡើងញឹកញាប់
- ភូមិគោលដៅមួយចំនួនស្ថិតនៅក្នុងតំបន់ប្រឈមទឹកជំនន់ញឹកញាប់ ដែលវាមិនបង្កលក្ខណៈងាយស្រួលសម្រាប់ការដាំដំណាំដែលមានរយៈពេលវែង
- ដំណើរការចលនាបង្កើតសហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់ប្រើពេលវេលាច្រើនជាងពេលវេលាដែលគ្រោង
- ការធ្វើការងាររួមគ្នាជាមួយកសិករទាមទាប្រើពេលវេលា
- ការផ្លាស់ប្តូរទំលាប់ពីការដាំដុះបែបប្រពៃណី ទៅជាការដាំដុះដំណាំថ្មីដែលមានតម្លៃខ្ពស់នៅលើទីផ្សា នៅតែមានឧបសគ្គដែលមានទំនាក់ទំនងគ្នា ដោយកត្តាចំណេះដឹង ការអនុវត្ត និងពត៌មានទីផ្សា

**ខ-មេរៀនពីគម្រោង**

- ធ្វើការជ្រើសរើសនិងកសាងសមត្ថភាពជនបង្គោលតាមភូមិ ហើយផ្ទេរការទទួលខុសត្រូវ ដែលជាការផ្តល់ភាពម្ចាស់ការនៅពេលដែលគម្រោងដកខ្លួនចេញ
- ការបំផុសការអនុវត្តកសិដ្ឋានដំណាំរយៈពេលយូរ គឺវាមានលក្ខណៈយុទ្ធសាស្រ្តជាងដំណាំរយៈពេលខ្លី ព្រោះវាធន់អាកាសធាតុ និងប្រមូលផលបានយូរអង្វែង
- សហគមន៍កសិកម្មគឺជាអង្គការមូលដ្ឋានថ្មីដែលនៅកៀកនិងប្រជាពលរដ្ឋ ងាយស្រួលចែករម្លែកពត៌មាន ធនធាន ហើយក៏ជាមធ្យោបាយថ្មីក្នុងការចលនាជម្រុញសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន
- តាមរយៈការផ្លាស់ប្តូរសិក្ខាសាលា និងទស្សនកិច្ចសិក្សាធ្វើអោយកសិករងាយរៀនសូត្របានលឿនជាងការបណ្តុះបណ្តាលផ្តល់តែទ្រឹស្តី
- ការជម្រុញការយល់ដឹងផ្នែកមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុ វាពិតជាអាចជួយអោយកសិករមើលឃើញការធ្វើកសិកម្មទៅជាការធ្វើជំនួញ
- ការបង្កបង្កើនផលគួរតែអោយបន្សាំទៅនឹងបរិបទប្រែប្រួលអាកាសធាតុ ប៉ុន្តែយើងក៏កំពុងរៀនពីរបៀបដែលអាចធ្វើអោយមានការឆ្លើយតបមានប្រសិទ្ធភាព

គម្រោងទី២៖

| ឧបសគ្គរាំង | មេរៀនពីគម្រោង |
| --- | --- |
| សម្រាប់កុមារគួរសារពិបាកយកសារចំពោះកុមារដែលធ្វើការចំណាកស្រុក | កំណត់ពេលវេលាសមស្របដែលពួកគាត់ជួបជុំគ្នា |
| កុមារខ្លះមិនចង់ចូលរួម | បង្កើតកម្មវិធីផ្សេងៗលើកកំពស់ការចូលរួមរបស់កុមារ |
| បទល្មើសព្រៃឈើ នៅតែកើតមានឡើង និងជនល្មើសមានការគម្រាមដល់គណៈកម្មការ | បង្កើនការសហការជាមួយអាជ្ញាធរ។ បង្កើតFacebook តាមសហគមន៍នីមួយៗ |

| | |
|---|---|
| | ក្នុងផ្សព្វផ្សាយពីរបាយការណ៍ និងពត៌មានផ្សេងៗក្នុងសហគមន៍។ |

## VI. ផែនការទិសដៅការងារបន្ត

**គម្រោងទី១៖**

ចន្លោះឆ្នាំ២០១៤ ដល់ ២០១៦ អង្គការកែប្រែសហគមន៍បានធ្វើការពង្រឹងអង្គការសហគមន៍ដែលមានស្រាប់ មានដូចជាសហគមន៍កសិកម្ម ក្រុម SHG និងVSLA។ ការរីកចម្រើនគម្រោងដូចមានរាប់រាប់ខាងលើ។ ម្យ៉ាងវិញទៀតអង្គការសហគមន៍គោលដៅទាំងនេះនៅមិនទាន់មានភាពរឹងមាំមែនទែននៅឡើយ ប៉ុន្តែយើងជឿជាក់ថាការខិតខំរួមគ្នា ជាបណ្តាញ ការចែករំលែកបទពិសោធន៍និងចំនេះដឹងអង្គការសហគមន៍គោលដៅទាំងនេះនឹងអាចបន្តពង្រឹងសមត្ថភាពខ្លួន ក្នុងពេលដែលអង្គការកែប្រែសហគមន៍កំពុងតែឈានទៅបន្តទៅមួយជំហ៊ានថែមទៀតដើម្បីធានានូវប្រសិទ្ធិភាព ហើយនឹងនិរន្តរភាពសម្រាប់ក្នុងឆ្នាំ២០១៧បន្តខាងមុខ។ ការផ្តួចផ្តើមបង្កើតជាសហភាពសហគមន៍កសិកម្មសម្រាប់ខេត្តសៀមរាប ដែលទាមទារអោយមានការទទួលស្គាល់ផ្លូវច្បាប់ នីតិវិធី និងគាំទ្របច្ចេកទេសក្នុងក្រោមការសម្របសម្រួល ជាមួយនាយកដ្ឋានសហគមន៍កសិកម្ម របស់ក្រសួងកសិកម្ម ហើយនឹងការជួយកសាងសមត្ថភាពសហភាពសហគមន៍កសិកម្មផងដែរ។ ទន្ទឹមនឹងនោះដែរអង្គការកែប្រែសហគមន៍នឹងបន្តផ្តោលើការកសាងសមត្ថភាពការអភិវឌ្ឍមុខជំនួញ ការគ្រប់គ្រងដល់សហគមន៍កសិកម្មទាំង១២ក្នុងខេត្តសៀមរាប។

**គោលដៅគម្រោង**

កាត់បន្ថយភាពក្រីក្រដោយការពង្រឹងសេដ្ឋកិច្ចកសិករ និងអង្គការសហគមន៍

**គោលបំណងគម្រោង**

បង្កើនភាពសកម្មរបស់អង្គការសហគមន៍ដើម្បីនិរន្តរភាពទិន្នផលកសិកម្មនិងកែលំអរប្រាក់ចំណូលទៅដល់ប្រជាសហគមន៍ជនបទក្នុងខេត្តសៀមរាប

- សហភាពសហគមន៍កសិកម្មមួយនឹងត្រូវបង្កើតដោយមានការទទួលស្គាល់ផ្លូវការដោយក្រសួងកសិកម្ម
- ជំនួញមួយរបស់សហភាពសហគមន៍កសិកម្ម ត្រូវបានរៀបចំក្នុងផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តត្រូវបានចូលរួមអនុម័តដោយសមាជិកសហគមន៍
- យ៉ាងហោចណាស់ជំនួញ២បន្ថែមត្រូវបានដាក់អោយដំណើរការក្នុងមួយសហគមន៍ក្នុងចំនោមសហគមន៍ទាំង១២ ហើយមានប្រាក់ចំណូលកើន២០%
- យ៉ាងហោចណាស់ក្រុម SHGs៥និងបំលែងទៅជាក្រុមនិងអនុវត្តគោលគារណ៍ VSLA
- យ៉ាងហោចណាស់ក្រុម SHGs២៥បន្ថែមត្រូវបានជួយគាំទ្រតាមរយះគម្រោង
- យ៉ាងហោចណាស់ក្រុម SHGs១០ដែលត្រៀមច្របាច់បញ្ចូលក្រុមទៅក្នុងសហគមន៍កសិកម្ម

- សមាជិកសហគមន៍កសិកម្ម៦០០នាក់ និងសមាជិក SHGs/VSLA៣០០ នឹងត្រូវបានពង្រឹងភាពម្ចាស់ការតាមរយៈការទទួលបាននូវចំណេះដឹងគោលការណ៍ HRBA/Study cycle
- សហភាពសហគមន៍កសិកម្មមួយនឹងត្រូវភ្ជាប់ទៅបណ្តាញកសិកម្មថ្នាក់ជាតិ
- ទីផ្សារជំនួញរបស់សហភាពសហគមន៍កសិកម្មមួយនឹងត្រូវបង្កើតក្នុងក្រុងសៀមរាបដើម្បីទទួលទិញផលិតផលរបស់សមាជិក

**គម្រោងទី២៖**

លទ្ធផល.1: សមាជិកសហគមន៍ព្រៃឈើទាំងបីសហគមន៍សរុប3,226នាក់ ស្រី1,555នាក់ និងបណ្តាញសហ គមន៍ព្រៃឈើទាំង១៣ ធ្វើការគ្រប់គ្រង ថែរក្សានិងដកហូតធនធានពីព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។

1.1 គាំទ្រការទុបស្កាត់បទល្មើសកាប់ឈើ និងរុករានដីព្រៃសហគមន៍ខុសច្បាប់នៅក្នុងដែនព្រៃរបស់សហគមន៍
1.2 ប្រជុំប្រចាំឆមាសបណ្តាញព្រៃឈើថ្នាក់ខេត្ត១៣សហគមន៍
1.3 គាំទ្របណ្តាញសហគមន៍ក្នុងការដោះស្រាយបទល្មើសព្រៃឈើថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
1.4 បណ្តុះបណ្តាលច្បាប់ស្តីពីព្រៃឈើ និងអនុក្រិតនៃការបង្កើតសហគមន៍ព្រៃឈើសម្រាប់អ្នកដែលជាប់ឆ្នោតថ្មី
1.5 ប្រជុំបណ្តាញសហគមន៍ព្រៃឈើជាមួយអាជ្ញាធរពាក់ព័ន្ធថ្នាក់ខេត្ត
1.6 ការធ្វើប្រឡាយព្រំពសហគមន៍
1.7 ការប្រជុំគណៈកម្មការសហគមន៍ជាមួយសមាជិកពិភាក្សាក្នុងការដាំដំណាំយុទ្ធសាស្រ្តតាមព្រំប្រទល់ព្រៃសហគមន៍ ភ្នំដងរែកសម្រែកព្រៃស្រស់ និងរតនរុក្ខា
1.8 ធ្វើបច្ចុប្បន្នភាពព្រៃសហគមន៍ព្រៃឈើទាំងបី
1.9 វេទិកាស្វែងរកដំណោះស្រាយតាមវិទ្យុ ទូរទស្សន៍ ពីសមាជិក រៀបចំពិធីអំពាវនាវក្នុងព្រៃ
1.10ស្នើសុំ និងជួបពិភាក្សាជាមួយអភិបាលខេត្ត និង ជួបជាមួយរដ្ឋមន្រ្តីក្រសួងកសិកម្មរុក្ខា ប្រមាញ់និងនេសាទ
1.11ប្រជុំថ្នាក់ស្រុកដំណោះស្រាយព្រំប្រទល់ព្រៃស្រស់ និងរំដួលវាសនា
1.12ប្រជុំបណ្តាញសហគមន៍ព្រៃឈើថ្នាក់ជាតិ
1.13បង្ហាត់បង្ហាញបន្ថែមជាប្រចាំនិងធ្វើការតាមដានឆ្លុះបញ្ជាំងដល់គណៈកម្មការក្រុមសន្សំ២១ធនាគារស្រូវ៨ដើម្បីអោយពួកគាត់អនុវត្តលក្ខន្តិកៈតួនាទីនិងការទទួលខុសត្រូវនិងនីតិវិធីក្នុងការគ្រប់គ្រងក្រុមទាំងពីរអោយមានប្រសិទ្ធិភាព
1.14.ប្រជុំឆ្លុះបញ្ជាំង១ឆ្នាំម្តង(ក្រុមសន្សំ២១និងធនាគាស្រូវ ៨ និងកសិករគំរូ១៧
1.15.កែលំអរធនាគារស្រូវ8 ធ្វើផ្លាកសញ្ញា5 និងដាក់ផ្លាកសញ្ញាបន្ថែមទៀតមានភូមិគោកច្រេស ភូមិឆ្វើប បាក់និមកូនដំរី និងភូមិសំបួរមាស។
1.16.ប្រជុំបណ្តាញសន្តិសុខស្បៀងថ្នាក់ជាតិ១ឆ្នាំ៣ដង

លទ្ធផលទី2៖ កុមារចំនួន៧៣១នាក់ កុមារី៤១៣នាក់ ស្ថិតនៅឃុំសំរោង បន្សាយរាក់និងគោកខ្ពស់មានការចូលរួមយ៉ាងសកម្មក្នុងការអភិឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។

សកម្មភាពគូសារ

2.1. សកម្មភាពគូសារ

2.2. ប្រជុំគ្រូស្មគ្រ័ចិត្តចំនួន២៦នាក់រៀងរាល់៣ខែម្តង

2.3. គាំទ្រសម្ភារៈក្លិបកុមារ

លទ្ធផលទី3៖CTOជាស្ថាប័នដែលមានគណនេយ្យភាព និងតម្លាភាពចំពោះម្ចាស់ជំនួយ និងអ្នកទទួលផល

3.1 ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ

3.2 ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំត្រីមាស

3.3 រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ ២០១៧

3.4 .ចូលរួមសិក្ខាសាលាភាពជាដៃគូរប្រចាំឆ្នាំ

3.5 .ការចូលរួម និងប្រជុំជាមួយបណ្តាញផ្សេងៗ AAC, NEP, WGPD, CHF, NGO forum

សៀមរាបថ្ងៃទី............ខែ.................... ឆ្នាំ២០១៦

**រៀបចំរបាយការណ៍ដោយ**

**ត្រួតពិនិត្យដោយ................**